សារព័ត៌មាន ខ្មែរផុស ស.រ.អា

**KhmerPost USA**

Advertising: **PA/NJ/NY: (267) 253-3947 MA/RI: (978) 656-8141**

មាតិការឿង — **Vol 07 Issue 126-March22nd- April 07th. 2013** — ទំព័រ



១-ខ្មែរអ្នកជាតិនិយម....................................០៤
២-អ្នកមានទិងអ្នកក្រនៅប្រទេសខ្មែរ....................................០៥
៣-បុណ្យរំលឹកគុណដល់វិញ្ញាណវីរបុរសខ្មែរកម្ពុជាក្រោម..........១៣
៤-The Cambodia daily..........................០៦និង០៩
៥- ម៉ម សុណង់ដូ រួចទោសជាប់ពីពន្ធនាគារ......................១៥
៦-ការបោះឆ្នោតសកលក្នុងកម្ពុជា នាខែកក្កដា....................១៤



32 Wamesit St., Lowell, MA 01852. **Phone-Fax (978) 656 8141** www.khmerpost.us


## វិចារណកថា

# រាត្រីក្លឹបសារព័ត៌មាន នៅឡូវែល



**ដោយ : ពិន សំខុន**

នៅពីរសប្តាហ៍មុខឱកាសចូលឆ្នាំម្សាញ់ព.ស ២៥៥៧ កាសែតខ្មែរផុស ស.រ.អា នឹងរៀបចំធ្វើសកម្មភាព "ក្លឹបសារព័តិមាន"ដ៏ពិសេសជាលើកទី២ ដើម្បីជូនជាកិត្តិយសដល់សមាគមន៏ខ្មែរនៅរដ្ឋមាសាឈូសែតដែលបានមករួមរស់នៅយ៉ាងកកកុញប្រមាណជាង៣០ឆ្នាំមកហើយ ជាមួយនឹងសមាគមន៏អាមេរិកាំងនឹងសាសន៏ដទៃឯទៀត ចំរុះច្រើនពណិសម្បុរពិធីនោះនឹងប្រារព្ធឡើងនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០១៣វេលាម៉ោង៦ល្ងាច ។

នារាត្រីនោះ ខ្មែរផុស ចង់បង្ហាញដល់សាធារណៈជនក្នុងនាមនៃសមាគមន៏ **តទៅទំព័រទី ០៣**

# ឆាកជីវិត អៀង សារី បងធំទី៣

## * លាចាកលោកទាំងបិទភ្នែកពុំជិត



▸▸ ការស្លាប់របស់ជនត្រូវចោទ អៀង សារី បានធ្វើឱ្យកង្វល់ពីដំណើរការសាលាក្តីកាន់តែត្រូវបានមើលឃើញ **តទៅទំព័រទី ១១**


**Collegiate Charter School of Lowell**

សាលារៀនអន្តរជាតិ និងបើកថ្មី បង្រៀន_សម្រាប់ទៅមហាវិទ្យាល័ ផ្តើមបើក នៅខែកញ្ញា ២០១៣ នេះហើយ ហើយផ្តល់សេវាឱ្យសិស្សតាំងពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី៩

**អនុវិទ្យាល័យ ឆាទ័រ នៃក្រុងឡូវែល**

**ផ្តើមចុះឈ្មោះ ហើយ !**

- កម្មវិធីត្រៀមទៅវិទ្យាល័យ
- មានឯកសណ្ឋានសិស្ស
- បង្រៀនចរិយាសម្បត្តិ
- សង្កត់លើគណិតវិទ្យា និង អង់គ្លេសខ្លាំង
- ពេលរៀនច្រើនក្នុង១ថ្ងៃ
- ក្រមចរិយាមានច្បាស់លាស់
- មានក្តីសង្ឃឹមខ្ពស់
- សាស្ត្រាចារ្យមានសញ្ញាប័ត្រខ្ពស់
- ការចូលរួមរបស់ឪពុកម្តាយ
- កម្មវិធីកំសាន្តក្រៅយ៉ាងសប្បាយ
- កម្មវិធីមុននឹងក្រោយម៉ោងរៀន
- កន្លែងថ្មីស្អាត និងសុវត្ថិភាព
- ពង្រីកដល់សាលាដែលមាន ថ្នាក់ក៏រិត១២
- សិក្សាឥតយកតម្លៃជាសាធារណៈ



**ការិយាល័យចុះឈ្មោះ**

1857 Middlesex Street, Lowell, MA 01851

Phone: (978) 458-1399

E-mail: LCCS@sabis.net

www.LCCS.SABIS.net

Member of the SABIS® School Network


Pin Samkhon
Soben Pin
KhmerPost USA
PRESS CLUB | LOWELL | MA
3RD ANNUAL MEDIA & COMMUNITY BUILDING GALA
CELEBRATING THE CAMBODIAN NEW YEAR
Pailin Restaurant
68 Branch Street. Lowell, MA 01851
Friday March 29th, 2013. 6:00 PM – Midnight.
Fine Asian Cuisines | Cash Bar | Live Performances | Much More
Formal Attire
RSVP: KhmerPostUSA@gmail.com
Tickets: $30 Advance purchase | $35 after March 25th
Soben Pin: (978) 942-1641 / (267) 253-3947
តន្ត្រីយ៍មាស
Panharee Thang
បញ្ញារី ថៃង សិល្បការិនីជំនាន់ថ្មី
មកពីហ្វីឡា
"រាត្រីក្លឹបសារព័ត៌មានឆ្នាំទី៣នៅឡូវែល
រដ្ឋម៉ាសាឈូសេតប្រារព្ធនាឱកាសចូលឆ្នាំថ្មីខ្មែរ"
*សូមសាធារណជនអញ្ជើញចូលរួមសម្តែងមតិក្នុងក្លឹបសារព័ត៌មាន (ម៉ោង៦ដល់៨:៣០)
និងរីករាយជាមួយការលៀងភោជនីហារ និងរាំកំសាន្តជាមួយក្រុមតន្ត្រីសម័យ
"តន្ត្រីយ៍មាស"នាពេលបន្តបន្ទាប់ -កុំភ្លេចនាំក្រុមគ្រួសារ និងញាតិមិត្តមករួមកំសាន្ត!
*នៅមានកម្មវិធីប្លែកៗខ្លះទៀត សំរាប់កំដរបរិយាកាសអឹកធឹកនាឱកាសចូលឆ្នាំថ្មីដែរ
Event Sponsors
AccuCare
Accucare Homecare Agency
CAREGIVER™ HOMES of Massachusetts
CENTRAL PHARMACY
Allston, MA
Kavei Entertainment
SILA Records
SWH
SENIOR WHOLE HEALTH
Simple. Secure. Independent.
Lowell General Hospital



ទិដ្ឋភាព"ប្រេសក្លឹប"នៅវ៉ូប៊ឺនឆ្នាំ២០១២

តពីទំព័រទី ០១

# រាត្រីក្លឹបសារព័ត៌មាននៅឡូវែល

ខ្មែរនូវមោទនភាពនៃការលើកតំកើងច្រើនជ្រុងជ្រោយនៃធនធានសង្គមបង្ហាញឡើងដោយម្ចាស់ផលិតកម្មរៀងៗខ្លួន ហើយម្យ៉ាងវិញទៀត ក៏បង្ហាញថា ខ្មែរក្នុងចំណោមសាសន៍អាស៊ីជានរណា ? ចង់រួមរស់ស្មើមុខមាត់អ្នកដទៃទៀតរបៀបណាដែរ ?

លោកអ្នកនឹងចូលរួមជាសាធារណៈជាមួយនឹងកម្មវិធីដែលមានពីរវគ្គគឺ វគ្គទី១ : "ក្លឹបសារព័តិមាន" នៃវត្តមានវាគ្មិនថ្នាក់ដឹកនាំសង្គមតំណាងអង្គការឯកជន ឬសាធារណៈអ្នកធ្វើនយោបាយ ពាណិជ្ជករម្ចាស់រោងចក្រ ឬប្រជាពលរដ្ឋធម្មតា...មកសម្តែងពីជំនាញ និងវត្ថុបំណងរបស់ខ្លួនក្នុងការបំរើសេចក្តីត្រូវការនៃពលរដ្ឋក្នុងតំបន់ វគ្គទី២ : "រាត្រីស្រមោសរ"ការរាំកម្សាន្ត នាឱកាសចូលឆ្នាំថ្មីកំដរក្រុមតន្ត្រី"ឥន្ទ្រីយ៍មាស" ដែលធ្លាប់ទទួលការកោតសរសើរ និងមានបទពិសោធន៍ច្រើនឆ្នាំក្នុងវគ្គនេះ ក៏មានបង្ហាញនូវស្នាដៃជាទេពកោសល្យរបស់កូនខ្មែរជំនាន់ថ្មីដែលនឹងត្រូវទៅប្រកួតថ្មីដៃជាមួយសិល្បៈករពិភពលោកផងដែរ ។

នៅមានវគ្គមួយទៀតដែលភ្ជាប់វគ្គទាំងពីរនេះរួមគ្នា គឺភោជនីយដ្ឋាន"ប៉ៃលិន"ដែលមានការរៀបចំជាលក្ខណៈអន្តរជាតិមានទទួលភេសជ្ជៈ មានសាលឆាកសម្រាប់ " ប្រេសក្លឹប" និងឆាកភ្លេងផ្សេងគ្នានៅក្នុងសាលដ៏ធំទូលាយថ្មីស្អាតមួយទៀត ។ ភ្ញៀវទាំងអស់នឹងឃើញនូវការរៀបចំតុបតែង តុ កៅអី និងម្ហូបអាហារដ៏ប្រណិតសាកសមនឹងការត្រៀមដំណើរនៃភោជនីយដ្ឋានថ្នាក់ប្រណិតនាកណ្តាល"ក្រុងខ្មែរ" ប្រកបដោយភាពរុងរឿងទៅរកអនាគតវែងឆ្ងាយនៃមុខរបរទទួលភ្ញៀវ ។

ព្រឹត្តិការណ៍ដ៏កម្រមាននៅសមាគមន៍នានានឹងដ៏ពិសេសសហគមន៍នានាដោយការយកចិត្តទុកដាក់ធ្វើឱ្យពិធីនា "រាត្រីក្លឹបសារព័តិមាន" ក្លាយជាឱកាសជួបជុំរីករាយតែមួយនឹងត្រូវផ្សព្វផ្សាយនៅប្រព័ន្ធទាក់ទងរបស់ខ្មែរផុសទៅដល់អ្នកអានរាប់ម៉ឺននាក់នៅតំបន់ផ្សេងៗឱ្យចូលរួមអបអរសាទរមានមោទនភាពជាខ្មែរដែលមានសំណាងកសាងភាពរុងរឿងដោយខ្លួនឯងបាន! ។

រុងរឿង ? គឺខ្មែរផុសបានបង្កើតយន្តការនៃការទាក់ទងគ្នាជូនដល់សង្គមខ្លួន ។ យន្តការនោះគឺក្នុងសង្គមសម័យតម្រូវឱ្យខ្មែរចេញពីភាពឯការទៅជួបប្រស្រ័យទាក់ទងស្មើភាពគ្នាជាមួយអ្នកដទៃ ជាពិសេសនៅក្នុងឱកាសដែលមានមនុស្សដែលមានឥទ្ធិពលលើសង្គមមកជួបជុំគ្នាច្រើននាក់ ។ គេនៅចាំបាននៅឡើយលទ្ធផលនៃ"ប្រេសក្លឹប" កាលពីឆ្នាំមុនពុំមានលេចឮថា ខ្មែរបែកបាក់ខ្មែរនិយាយអាក្រក់ពីអ្នកដទៃខ្មែរចូលចិត្តបង្កើតបក្ខពួក... ។ល ។ អ្វីសោះទេ..នេះគឺជាកាប្រែប្រួលដ៏សំខាន់មួយរបស់សង្គមខ្មែរ ។ ដូច្នេះឥរិយាបថរបស់យើងចំពោះព្រឹត្តិការណ៍ "ប្រេសក្លឹប" នេះគឺការអញ្ជើញចូលរួមប្រកាន់ការរួបរួមគ្នាដែលមានសីលធម៌គ្រប់គ្រាន់ -ទទួលយកការទិទានដែលគ្មានការប្រមាថ ឬប្រណែននិន្ទា -ទទួលយកការជួបអ្នកដទៃជាមិត្តរួមដំណើរទៅរកអនាគតភ្លឺស្វាង... ដែលត្រូវផ្តើម និងបន្តឥរិយាបថថ្មីនេះឱ្យបានខ្ជាប់ខ្ជួន ។

នារាត្រីដ៏ធម្មតាមួយដែលសហគមន៍ខ្មែរត្រៀមរៀបចំគ្រួសារធ្វើបុណ្យចូលឆ្នាំថ្មី ដូចសព្វមួយដងតែឆ្នាំនេះវត្តមាននៃខ្មែរផុសនៅឡូវែល ជា"អ្នកភូមិយើង" គឺជាអ្វីមួយដែលប្លែកទើបនឹងកើតឡើង ។ ទឹកមួយតំណក់ថ្មីនេះកំពុងធ្លាក់ទៅក្នុងកែវទឹកពេញមួយដោយនាំមកជាមួយនូវព័តិមានថ្មីៗដែលខ្មែរផុសត្រូវការសំរាប់ផ្លាស់ប្តូរនូវប្រព័ន្ធទាក់ទងដ៏ធំធេងដែលសង្គមខ្មែរថ្មីត្រូវការសំរាប់អភិវឌ្ឍន៍នូវជំនួយស្មារតី រៀងរាល់ខែ២សប្តាហ៍ម្តងសំរាប់មិត្តភាព និងក្តីសង្ឃឹមថ្មី...ទាំងនោះ នឹងធ្វើឱ្យទឹកដែលហៀរចេញពីមាត់កែវទៅជួបសមុទ្រដ៏ធំធេងខៀវស្រងាត់កញ្ជ្រោកបោកបាចរបស់សហរដ្ឋអាមេរិកដែលកំពុងរង់ចាំសមាគមន៍ខ្មែរជាយូរមកហើយ ។

នៅមានមនុស្សជាច្រើនពុំមានការចាប់អារម្មណ៏ពីខ្យល់ថ្មីនៃខ្មែរផុសនៅឡើយ ។ នៅថ្ងៃទី២៩ ខែមិនាឆ្នាំនេះកាសែតខ្មែរផុសមួយនេះចង់បង្ហាញថា នៅតំបន់ញូអិនក្លិននេះប្រាកដជាមានខ្យល់សម្បូរអុកស៊ីហ្សែនថ្មីមានសម្បត្តិថ្មីដែលធ្វើឱ្យលោកអ្នកដកដង្ហើមធូរក្នុងចិត្តមានអារម្មណ៏ល្អប្រកបដោយការងារក្នុង និងក្រៅផ្ទះដោយមានកម្លាំង និងសុខភាពប្រសើររាល់ថ្ងៃដោយមិនដឹងខ្លួន ។

ទោះជាចាប់អារម្មណ៏ ឬគ្មាន! មនុស្សម្នាក់ៗត្រូវតែថែសុខភាពដែលជាសម្បត្តិផ្ទាល់ខ្លួនមានសិទ្ធិនឹងជ្រើសរើសចម្រាញ់យកខ្យល់ល្អដែលខ្លួនត្រូវការសំរាប់ដកដង្ហើមត្រូវការដឹងការពិតសំរាប់អារម្មណ៏ល្អ ដូច្នេះមានភារកិច្ច និងថែទាំសម្បត្តិផ្ទាល់ខ្លួននោះ ពុំអាចនរណារំលោភបាន ។ ឧទាហរណ៏នៃខ្យល់ល្អ គឺបរិយាកាសដែលធានាសន្តិភាពជាប្រចាំដែលបំពេរអារម្មណ៏ដោយលម្អរ ដោយការជួបជុំដោយប្រលោមលោក រីឯអារម្មណ៏ល្អកើតពីដំណឹងដែលពេលខ្លះល្អ ពេលខ្លះក៏អាក្រក់តែវិញ្ញាណជឿបានថាជារឿងដែល "ពិត" អាចពិចារណា និងធ្វើសេចក្តីសំរេចចិត្តបានដោយមិនមានភាពស្មុគស្មាញបង្កើតអារម្មណ៏មិនច្បាស់លាស់ ។ ជាមួយប្រព័ន្ធផ្សព្វផ្សាយដែលមានការទទួលខុសត្រូវខ្ពស់ចំពោះសាធារណៈជនអ្នកទទួលព័តិមាន និងមានការធានាថា ខ្លួនមុខជាទទួលយកនូវខ្យល់បរិសុទ្ធ និងអារម្មណ៏ល្អនោះបាន ។

ប្រវត្តិនៃការប្តូរប្រទេសរបស់សហគមន៍ខ្មែរជិតដាមដោយស្នាមជូរចត់នៃទារុណ្ណកម្មនៃការភ័យខ្លាចនៃការអត់ឃ្លាននៃការព្រាត់ប្រាស់ ។ ៣០ឆ្នាំក្រោយមកស្លាកស្នាមនៅតែមិនទាន់រលុបបាត់ ហើយថែមទាំងរាលដាលឆ្លងដល់កូនចៅច្រើនដំណរថែមទៀត ។ នាឱកាសក្នុងពិធីបុណ្យចូលឆ្នាំថ្មីនេះខ្មែរផុសមានតែជូនពរគ្នាឱ្យការប៉ុងប៉ងស្វែងបញ្ឈប់ការឈឺខ្លោចផ្សាធ្វើបានសំរេចជាស្ថាបពរជារៀងរហូត ហើយសុំឱ្យសេចក្តីសុខទាំង៥ប្រការកើតមានដល់លោកអ្នកក្នុងឆ្នាំនេះកុំបីឃ្លៀងឃ្លាត់ ៕

# ខ្មែរអ្នកជាតិនិយម

តពីលេខមុន

ស្វាហាប់ និងមានសកម្មភាពជានិច្ច ។ ដោយសារុបយួនជាជនជាតិមានគុណសម្បត្តិច្រើនដែលធ្វើឱ្យបារាំងព្រួយបារម្ភ ព្រោះសាសន៍នេះមិនចូលចិត្តជនបរទេសទេ ហើយមិនសុខចិត្តនៅក្រោមអាណាព្យាបាលអ្នកដ៏ទៃឡើយ ។

អាស្រ័យហេតុនេះ ដើម្បីឱ្យជនជាតិយួនសុខចិត្តជួយខ្លួន ក្នុងការក្ដោបក្ដាប់អំណាចនេះ និងដើម្បីកុំឱ្យយួនធ្វើសកម្មភាពប្រឆាំងភ្លាម១ ក្នុងការត្រួតត្រារបស់ខ្លួននោះ បារាំងក៏បានធ្វើនយោបាយជួយប្រទេសយួនឱ្យចំរើនគ្រប់វិស័យ ។ ក្នុងផ្នែកសេដ្ឋកិច្ចបារាំងបានបង្កើតមណ្ឌលកសិកម្មរោងឧស្សាហកម្ម,គមនាគមន៍ទាំងផ្លូវ ទឹកទាំងផ្លូវគោក, កំពង់ផែ, គ្រឹះស្ថានជំនួញ ។ល ។ ខាងផ្នែកសង្គមកិច្ចបារាំងបានរៀបចំឱ្យមានមុខរបរមានការងារធ្វើ, មន្ទីរពេទ្យ,ទីកំសាន្ត លំហែកាយ ។ល ។ ផ្នែកអប់រំនិងវប្បធម៌បារាំង បានបង្កើតសាលាសាធារណៈជាច្រើន រហូតដល់ភូមិស្រុកដាច់ស្រយាល, បង្កើតមន្ទីរស្រាវជ្រាវ និងវិទ្យាស្ថានផ្សេង១, បង្កើតវិទ្យាល័យ និងមហាវិទ្យាល័យដែលបង្ហាត់មុខវិជ្ជាជាន់ខ្ពស់ ជួយជាតិយួនឱ្យមានតម្រិះលូតលាស់ មិនចាញ់បារាំងឡើយ ។ ដែលបារាំងជួយយួននេះក៏គឺដើម្បីបង្ហាត់យួនឱ្យចូលក្របខ័ណ្ឌបំរើរដ្ឋការ


និពន្ធដោយ ឡឹក សំអឿន ហៅ "ផ្កាយព្រឹក"

អាណានិគមបារាំងនៅក្នុងប្រទេសយួនផង នៅប្រទេសដទៃទៀតនៃឥណ្ឌូចិនបារាំងសែសផង ។

នយោបាយរបស់បារាំងនេះតម្រូវឱ្យយួនសុខកាយសប្បាយចិត្ត និងព្រមទទួលដោយរីករាយ ព្រោះវាស្របនឹងបំណងរបស់យួនល្អណាស់ក្នុងការបញ្ចេញប្រជាជនយួន ដែលមានចំនួនច្រើនហួសកំរិតនោះ ឱ្យទៅនៅប្រទេសដ៏ទៃទៀត ជាពិសេសគឺប្រទេសកម្ពុជា ដើម្បីជានយោបាយទន្ទ្រានយកទឹកដីខ្មែរ នៅពេលណាដែលចៅហ្វាយនាយ( បារាំង) ត្រូវដកខ្លួនចេញពីឥណ្ឌូចិន ។ មិនតែប៉ុណ្ណោះ ដើម្បីជួយនយោបាយបារាំងឱ្យមានដំណើរស្រួលទៅមុខ និងដើម្បីឱ្យបារាំងទុកចិត្តលើយួនកាន់តែខ្លាំងឡើងនោះ យួនបានប្រើនយោបាយស្រីស្រស់ យកទៅអនុវត្តលើជនជាតិបារាំងទាំងអ្នកកាន់អំណាចអ្នកជំនួញថែមទៀតផង ។

## បារាំងជៀសវាងពូជខ្មែរ

ចំណែកកម្ពុជាវិញ កាលបារាំងមកដល់ បារាំងកត់សម្គាល់ថា កម្ពុជាជាប្រទេសមួយយ៉ាងចាស់កំរិល ហិនហោច ត្រុឌទ្រោម ដោយសារសង្គ្រាមនិងអំពើបង្ខិនបង្ខោចជិះជាន់ពីប្រទេសជិតខាងរាប់សតវត្សមកហើយ, ខ្មែរជាពូជនៃជនជាតិចាញ់គេចាញ់ធម្មជាតិ ចាញ់មនុស្ស និងចាញ់ខ្លួនឯង ជាសង្គមនៃមនុស្សដែលរស់នៅដោយការខ្លាចភិតភ័យនៅអន្លង់អវិជ្ជា ដែលបរិបូណ៌ទៅដោយជំនឿផ្ដេសផ្ដាសអកុសល ឥតហេតុផល ។ អ្នកនិពន្ធបារាំងជាច្រើននាក់បាននាំគ្នាសរសេរបន្តុះបង្អាប់មើលងាយពូជសាសន៍ខ្មែរនៅក្នុងសៀវភៅជាច្រើន។ នៅក្នុងសៀវភៅមួយឈ្មោះ "ឥណ្ឌូចិន" បោះពុម្ពផ្សាយពីឆ្នាំ១៩០០ អ្នកនិពន្ធបានកត់សម្គាល់ថា "ប្រជាជនកម្ពុជាទំនងជាខ្លាំងជាងប្រជាជនវៀតណាមខាងកម្លាំងកាយមែនតែខ្វះសមត្ថភាព គ្មានកំរិតខ្លួនឯង ពឹងផ្អែកតែលើអ្នកដទៃ ជាជនជាតិល្ងង់ខ្លៅឥតតម្រិះវិជ្ជា ឥតប្រាជ្ញា ធ្វើ១តាមគេទាំងស្រុង ឥតមានការត្រិះរិះពិចារណាសោះឡើយ ។ ដោយផ្ទុយទៅវិញនៅវៀតណាម ជនជាតិវៀតណាមទោះជាក្រីក្រយ៉ាងណាក្ដី ទោះជាគ្រួសារធំតូចក្ដី ក៏នៅតែមានការអប់រំស្មើរតែទាំងអស់គ្នា ។ ខាងផ្លូវចិត្តវិញ ខ្មែរខ្វះសាមគ្គី ឥតមានមនសិកាជាតិសោះ ឥតទាំងយល់ថាមាតុភូមិជាអ្វីផង ។ ដោយសរុបជនជាតិខ្មែរអន់ជាងជនជាតិវៀតណាម យ៉ាងឆ្ងាយគ្រប់វិស័យ សូម្បីប្រាក់ចំណូលមែនទែនរបស់ស្ដេចខ្មែរ ក៏សុទ្ធតែបានមកពីយកពន្ធលើល្បែងស៊ីសង ដែលជនជាតិឯទៀតជាអ្នកកាន់កាប់ចិន, ចាម, ជ្វា, យួនជាដើម ។

នៅក្នុងសៀវភៅឈ្មោះ "ទំនៀមទំលាប់ខ្មែរ" ដែលបោះពុម្ពផ្សាយពីឆ្នាំ១៩៣៨ អ្នកនិពន្ធបានកត់ត្រាទុកថា "ជនជាតិខ្មែរទាំងឡាយ ដែលអួតអាងថា ខ្លួនជាអ្នកចេះដឹងនោះ ច្រើនតែមិនសូវមានប្រាជ្ញាឈ្លាសវៃមិនសូវមានចំណេះអ្វីប្រាកដទេ ហើយឥតរវល់យកចិត្តទុកដាក់អ្វីទាំងអស់ក្នុងកិច្ចការសង្គម ពូកែខាងវាយឫកថា ខ្លួនជាពូជខ្មែរអង្គរនៅចំពោះមុខជនជាតិអឺរ៉ុប ហើយធ្វើតាមជនជាតិអឺរ៉ុបតាំងពីឫកពាររហូតការរស់នៅប្រចាំថ្ងៃ ដើម្បីឱ្យអ្នកនៅក្រោមបង្គាប់ខ្លបខ្លាច ។ ពួកនេះសុទ្ធសឹងជាអ្នកសុខចិត្តរស់នៅក្រោមម្លប់បារមីនៃអ្នកមានអំណាចដូចជាអាទិទេព ដែលគ្រប់គ្រងសង្គមខ្មែរ ។ រីឯនៅបាតសង្គមវិញ សុទ្ធតែជារាស្ត្រល្ងង់ខ្លៅក្រីក្រតោកយ៉ាកមានមុខរបរ ជាអ្នកស្រែចំការតូចតាច រស់នៅក្នុងពិភពមួយពោរពេញទៅដោយជំនឿផ្ដេសផ្ដាសអកុសលប្រាសចាកហេតុផលគ្មានការពិតចូលចិត្តជឿទៅលើអច្ឆរិយវត្ថុ, អារក្ស , អ្នកតា, មន្តគាថា, អាគមឱមអាម ។ល។

តទៅលេខក្រោយ






# អ្នកក្រ និងអ្នកមាននៅប្រទេសខ្មែរ ភាគទី៧

**គីមសុស**


គីម សុស មន្ត្រីចូលនិវត្ត ក្រសួងការបរទេស សហរដ្ឋអាមេរិក

តើរដ្ឋាភិបាលជួយអ្នកជំនួញតាមផ្លូវច្បាប់យ៉ាងម៉េច ខ្លះដើម្បីឱ្យអ្នកជំនួញសម្រេចគោលដៅបាន?

មុននឹងដោះស្រាយសំនួរនេះ សុំរំលឹកទ្រោះៗអំពីអ្វីដែលបាននិយាយពីមុន។

នៅពេលមុនមានការវែកញែកអំពីថាតើរដ្ឋាភិបាលគួរធ្វើយ៉ាងម៉េចជួយឱ្យអ្នកជំនួញបានចំណេញជួយឱ្យមានផ្សារជួយឱ្យមានកន្លែងធ្វើជំនួញឯទៀតឱ្យបានកាន់តែច្រើនឡើង ជួយឱ្យមានចំនួនអ្នកជំនួញកាន់តែច្រើនឡើង គឺជួយដោយផ្អែកទៅលើគោលការណ៍ស័ក្តិសិទ្ធិបី គឺ កន្លែង កន្លែង និងកន្លែង (យើងនឹងវិភាគចំណុចនៅពេលក្រោយ) ដើម្បីបង្កើតឱ្យមានចំនួនការងារដែលផ្តល់នូវតម្លៃប្រាក់ឈ្នួលសមស្របតាមតម្លៃប្រាក់ឈ្នួលទីផ្សារកាន់តែច្រើនឡើង ច្រើនឡើងឱ្យទាន់ចំនួនអ្នករកការងារធ្វើ។

សូមបញ្ជាក់ថា និយាយនេះមិនមែនមានន័យថា ស្នើរសុំឱ្យរដ្ឋាភិបាលលូកដៃចូលក្នុងសកម្មភាពនៃជំនួញទេ តែវាមានន័យថា រដ្ឋាភិបាលអាចចេញគោលការណ៍នយោបាយ និងគោលការណ៍ច្បាប់ដើម្បីធ្វើឱ្យគោលដៅនៃការចំរើនទៅមុខទាំងនោះបានសម្រេច។

យើងដឹងថាសេដ្ឋកិច្ចខ្មែរជាសេដ្ឋកិច្ចទីផ្សារមិនមែនជាសេដ្ឋកិច្ចដឹកនាំដោយការគ្រប់គ្រងពីរដ្ឋាភិបាលទេ។

សូមរំលឹកក្នុងសេដ្ឋកិច្ចទីផ្សារនេះ តាមទស្សនៈរបស់លោកអាដាំស្មិហ្ស (Adam Smith) សេដ្ឋវិទូជនជាតិស្កុត់នៅសតវត្សទី១៨ យើងយល់ថាជាសេដ្ឋកិច្ចលែងដៃមានន័យថាគ្មានការត្រួតត្រាពីរដ្ឋអំណាចគឺមានន័យដូចន័យនៅក្នុងអត្ថបទខាងក្រោមនេះដែលស្រង់ចេញពីប្រព័ន្ធអ៊ីនទ័រណិត (INTERNET)។

### laissez-faire economics

One of the guiding principles of capitalism, this doctrine claims that an economic system should be free from-government intervention or moderation, and be driven only by the market forces. Centered on the belief (termed invisible hand by the 18th century Scottish economist Adam Smith) that human beings are naturally motivated by self-interest and, when they are not interfered-with in their economic activities, a balancedsystem of production and exchange based on mutual benefit emerges....

គឺថា "សេដ្ឋកិច្ចលែងដៃ (សេដ្ឋកិច្ចសេរី ឬទុកឱ្យគេធ្វើកុំទៅប៉ះពាល់) ជាគោលការណ៍សម្រាប់ដឹកនាំមួយនៅក្នុងរបបសេដ្ឋកិច្ចមូលធននិយម។ ទ្រឹស្តីនេះប្រកាន់យកគំនិតថា ប្រព័ន្ធសេដ្ឋកិច្ចណាមួយក៏ដោយគួរតែទុកឱ្យមានដំណើរការដោយសេរីមានន័យថា រដ្ឋាភិបាលមិនត្រូវលូកដៃចូល ឬក៏ត្រូវកែសម្រួលអ្វីដែរ គឺថា ទុកឱ្យនៅតែក្រោមការដឹកនាំនៃកំឡាំង (សកម្មភាព) របស់ទីផ្សារ ។ លោក អាដាំ ស្មិហ្ស ADAM SMITH ដាក់ឈ្មោះទ្រឹស្តីនេះថាដៃដែលភ្នែកមើលមិនឃើញ (មានន័យថាសកម្មភាពដែលគ្មានអ្នកណាអាចយល់បាន) ប៉ុន្តែបានសម្រេចលទ្ធផលដ៏ប្រសើរនៅទីបញ្ចប់។ ទ្រឹស្តីនេះផ្តោតទៅលើជំនឿសំខាន់ថា មនុស្សតាមធម្មតា បើនឹងធ្វើអ្វីមួយទាល់តែមានប្រយោជន៍ផ្ទាល់ខ្លួន (មានន័យថាប្រយោជន៍ផ្ទាល់ខ្លួនញុាំងឱ្យមនុស្សប្រព្រឹត្តអ្វីមួយដែលទាក់ទងនឹងប្រយោជន៍នោះ) ហើយនៅក្នុងសកម្មភាពសេដ្ឋកិច្ចបើកាលណាគេទុកឱ្យមនុស្សប្រព្រឹត្តទៅដោយខ្លួនឯងគឺកុំឱ្យមានការជ្រៀតជ្រែកពីក្រៅប្រព័ន្ធយុត្តិធម៌មួយនៃការបង្កបង្កើតផលនិងការលក់ដូរដែលប្រកបទៅដោយផលប្រយោជន៍ផ្ទាល់ខ្លួនរវាងគ្នានិងគ្នានឹងលេចចេញមក។"

សុំបញ្ជាក់ថាចំណុចនេះមិនមែនមានន័យថាអ្នកជំនួញធ្វើអ្វីតាមតែចិត្តខ្លួនឯងបានទេ ។ អ្វីៗទាំងអស់ត្រូវតែប្រព្រឹត្តទៅតាមគន្លងច្បាប់។ បើការប្រព្រឹត្តនោះមិនដើរក្នុងក្របខ័ណ្ឌនៃច្បាប់ទេការប្រព្រឹត្តនោះនឹងអាចធ្លាក់ក្នុងភាពច្របូកច្របល់គ្មានរបៀបរៀបរយលើសលែង។ត្រង់នេះញុាំងឱ្យយើងនឹកទៅដល់ច្បាប់ធម្មជាតិដែលនិយាយអំពីធាតុចម្ហាយក្តៅសកម្ម(THERMODYNAMICS)។ ច្បាប់នោះចែងថា ភាពច្របូកច្របល់តែងតែស្ទុសសំដៅទៅរកភាពច្របូកច្របល់ហួសប្រមាណលើសលប់(ENTROPY TENDS TO GO TO MAXIMUM)។ត្រង់នេះមានន័យថា ភាពច្របូកច្របល់នឹងទៅដល់ភាពលើសលប់នោះ បើទុកឱ្យធ្វើបំណើរដោយខ្លួនឯង មិនរកមធ្យោបាយទប់ស្កាត់។

បើយើងសង្កេតឱ្យមែនទែនទៅច្បាប់ធម្មជាតិនេះមានន័យថា សកម្មភាពនីមួយៗ ដើម្បីឱ្យមានរបៀបរៀបរយត្រូវប្រព្រឹត្តទៅនៅក្នុងក្របខ័ណ្ឌច្បាប់។ ដូច្នេះអ្នកជំនួញមានសេរីភាពធ្វើអ្វីក៏បានឱ្យតែនៅ **តទៅទំព័រទី ០៧**


GATEWAY FAMILY DENTAL

NOW OPENED AT GATEWAY CENTER II (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



DR. SERENA B. CHUOP

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.




WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN
- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ែរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

MOST DENTAL INSURANCES ACCEPTED
INCLUDING MASSHEALTH FOR KIDS
FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស្វ៊ិន
Masshealth for Kids
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION
(978) 455-5044

www.gatewayfamilydental.com

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ អង្គារ៍ ទី០៥ ខែ មិនា ឆ្នាំ២០១៣

# លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ជាឱ្យ លោក ម៉ុង ឫទ្ធី សាងសង់ផ្ទះឱ្យអ្នកភូមិនៅស្រុកស្ទឹងហាវ

**កាំង ម៉េងហ៊ុន**
**ខេមបូឌា ដេលី**

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានច្រានចោលសេចក្តីសម្រេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០១១ ដើម្បីផ្តល់ដីទំហំ៥០ហិកតាក្នុងខេត្តព្រះសីហនុឱ្យទៅក្រុមហ៊ុនស្រាបៀរមួយ ដែលតាមសេចក្តីសម្រេចសម្រេចនោះ អ្នកភូមិ ៤៩គ្រួសារត្រូវបានអាជ្ញាធរបណ្តេញចេញដោយបង្ខំកាលពីដើមខែនេះ ។

នៅក្នុងលិខិតមួយច្រានចោលសេចក្តីសម្រេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីប្រគល់ដីនោះទៅឱ្យលោក ជាម ផែន ជាពាណិជ្ជករដើម្បីសាងសង់រោងចក្រស្រាបៀរលីអូក្នុងស្រុកស្ទឹងហាវនោះ លោក ហ៊ុន សែន បានមានប្រសាសន៍ថា ផ្ទះទាំងនោះនឹងត្រូវសាងសង់ឡើងវិញ ដោយប្រើប្រាក់របស់គ្រួសារលោកផ្ទាល់ ។ លោកមានប្រសាសន៍ថា លោក ម៉ុង ឫទ្ធី សមាជិកព្រឹទ្ធសភាគណបក្សប្រជាជនកម្ពុជានឹងទទួលបន្ទុកលើគម្រោងសាងសង់នេះ ។

លោក ហ៊ុន សែន បានសរសេរនៅក្នុងលិខិតចុះថ្ងៃទី១៧ ខែ មីនា ថា "បន្ទាប់ពីការបណ្តេញអ្នកភូមិ៤៩គ្រួសារចេញពីភូមិទឹកផុសស្រុកស្ទឹងហាវ ដោយលោក ជាម ផែន មកខ្ញុំ សូមស្នើរឱ្យលោក (ម៉ុង ឫទ្ធី )សាងសង់ជម្រកបណ្តោះអាសន្ន ដើម្បីឱ្យអ្នកភូមិទាំងនេះស្នាក់នៅសិន ហើយសាងសង់ផ្ទះសំរាប់ពួកគាត់ដោយប្រើប្រាស់ប្រាក់របស់គ្រួសារខ្ញុំ" ។

វិវាទដីធ្លីរវាងគ្រួសារអ្នកភូមិក្នុងខេត្តព្រះសីហនុ និងលោក ជាម ផែន កំពុងស្ថិតក្នុងកណ្តាប់ដៃសាលាឧទ្ធរណ៏ ប៉ុន្តែលិខិតរបស់លោក ហ៊ុន សែន មិនបានលើកឡើងពីរឿងក្តីនេះទេ ។

លោក ម៉ុង ឫទ្ធី ដែលបានស្ថិតនៅក្នុងភូមិកែវផុសកាលពីម្សិលមិញ បានមានប្រសាសន៏ថា កម្មកររបស់លោកបានចាប់ផ្តើមសាងសង់ផ្ទះជូនអ្នកភូមិឡើងវិញហើយ ហើយថាផ្លូវមួយខ្សែនៅក្នុងតំបន់នោះកំពុងត្រូវបានក្រាលកៅស៊ូឡើងវិញដែរ ។

លោកបានមានប្រសាសន៏ថា "យើងនឹងសាងសង់ផ្ទះដែលពួកគាត់បានបាត់បង់"អំឡុងការបណ្តេញចេញនោះឡើងវិញ ។

កាលពីម្សិលមិញ អ្នកភូមិបានសម្តែងក្តីសង្ឃឹមថា លោក ម៉ុង ឫទ្ធី នឹងជួយធ្វើឱ្យពួកគាត់ទទួលបានដីស្រែចម្ការរបស់ពួកគាត់ដែលទីស្តីការគណៈរដ្ឋមន្ត្រីបានប្រគល់ទៅឱ្យលោក ជាម ផែន នោះមកវិញ ។

អ្នកភូមិឈ្មោះ ឃួន ស៊ីថា បាននិយាយថា "លោកឧកញ៉ា ម៉ុង ឫទ្ធី ក៏បានមានប្រសាសន៏ផងដែរថា យើងនឹងទទួលបានដីស្រែចំការរបស់យើងវិញក្នុងពេលឆាប់ៗនេះ" ។

អ្នកស្រី ស៊ីថា បានមានប្រសាសន៏ថា "ខ្ញុំសូមថ្លែងអំណរគុណ...ហើយខ្ញុំគិតថា បញ្ហានេះនឹងត្រូវបញ្ចប់" ។ អ្នកស្រីបានបន្ថែមថា ឥឡូវនេះគ្រួសារអ្នកភូមិស្នើឱ្យសាលាឧទ្ធរណ៏ច្រានចោលរឿងក្តីនេះ ។

បទបញ្ជារបស់លោក ហ៊ុន សែន នេះបានកើតឡើងតែប៉ុន្មានខែប៉ុណ្ណោះនៅមុនការបោះឆ្នោតជាតិនៅខែកក្កដា ។

លោក បួន ណារិទ្ធ អ្នកសម្របសម្រួលប្រចាំខេត្តរបស់អង្គការសិទ្ធិមនុស្សលីកាដូបានមានប្រសាសន៏ថា "ប្រជាពលរដ្ឋកម្ពុជាសូមថ្លែងអំណរគុណដល់អ្នកដែលបានជួយពួកគាត់ ហើយអ្នកដែលទទួលបានជំនួយពីលោកនាយករដ្ឋមន្ត្រីនឹងបោះឆ្នោតជូនលោក " ។

*ប្រែសម្រួលដោយ សោម សារុន*

# សកម្មភាពតវ៉ាទាមទារប្រាក់សំណងរបស់អតីតបុគ្គលិកក្រុមហ៊ុន អឹមហ្វូន ឈានចូលដល់ថ្ងៃទី២

**អូន ភាព**
**ខេមបូឌា ដេលី**

អតីតបុគ្គលិកប្រហែល៣០០នាក់របស់ក្រុមហ៊ុនអឹមហ្វូន (Mfone)ដែលជាក្រុមហ៊ុនបម្រើសេវាទូរស័ព្ទក្បៀយធនបានបន្តធ្វើការតវ៉ានៅខាងក្រៅទីស្នាក់ការរបស់ក្រុមហ៊ុននេះក្នុងរាជធានីភ្នំពេញ ដែលបានបិទទ្វាររួចទៅហើយនោះ រហូតដល់ថ្ងៃម្សិលមិញ ដើម្បីទាមទារប្រាក់បំណាច់សរុបចំនួន៤,៤លានដុល្លារឱ្យបុគ្គលិកចំនួន១.០៩២នាក់ ។

ក្រុមអ្នកតវ៉ា និងមន្ត្រីបានឱ្យដឹងថា នៅពេលជាមួយគ្នានេះដែរ តំណាងនិយោជិតចំនួន១០នាក់បានជួបជុំជាមួយមន្ត្រីមកពីក្រសួងសង្គមកិច្ចដើម្បីដោះស្រាយបញ្ហាប្រាក់អតីតភាពការងារនោះ ។

លោក នឹម សូលីដា អតីតប្រធានគ្រប់គ្រងខាងវិស្វកម្មនៅក្រុមហ៊ុន អឹមហ្វូន ដែលបានចូលរួមក្នុងកិច្ចប្រជុំកាលពីម្សិលមិញបានមានប្រសាសន៏ថា "យើងស្នើសុំដល់រដ្ឋាភិបាលតាមរយៈក្រសួងឱ្យជួយផ្តល់កញ្ចប់ថវិកាមួយសម្រាប់បើកឱ្យពួកយើងទាំងអស់គ្នា ។ រដ្ឋាភិបាលមានលទ្ធភាពអាចយកថវិការនេះ(ពីក្រុមហ៊ុន) បានតាមសំណុំរឿងនៅតុលាការ" ។

ក៏ប៉ុន្តែលោក វង់ សាវ៉ាន អគ្គលេខាធិការរងគណៈកម្មាធិការដោះស្រាយវិវាទការងារនៅក្រសួងសង្គមកិច្ចបានមានប្រសាសន៏ថា រដ្ឋាភិបាលមិនអាចជួយក្រុមតវ៉ាបានទេ ពីព្រោះក្រុមហ៊ុនអឹមហ្វូន បានតែងតាំងអភិបាលមួយរូបឱ្យទទួលខុសត្រូវចំពោះបំណុលរបស់ខ្លួនហើយ ។

លោកថ្លែងថា "រដ្ឋាភិបាលមិនអាចជ្រៀតជ្រែកបានទេ" ។ លោកបន្តទៀតថា ក្រសួងសង្គមកិច្ចបានកំណត់ពេលបើកកិច្ចប្រជុំមួយទៀត ជាមួយអភិបាលក្រុមហ៊ុនអឹមហ្វូន និងក្រុមអ្នកតវ៉ានៅថ្ងៃនេះ ៕

*ប្រែសម្រួលដោយ ហួង កុកឡេង*

# Hun Sen Orders Homes of Evictees Rebuilt

**By Kaing MengHun**
**The Cambodia Daily**

Prime Minister Hun Sen has overruled at 2011 decision by the council of Ministers to grant 350 hectares of land in Preah Sihanouk province-from which 49 families were forcefully evicted by authorities earlier this month-to a brewery.

In a letter dismissing the Council of Ministers' decision to grant the land to businessman Cheam Phen to build a Leo Beer factory in Stung Hav district, Mr. Hun Sen said the homes would be rebuild using money from his own family's wealth. He said CPP Senator Mong Riththy would be in charge of the project.

"After the eviction of 49 families from Stung Hav's Keo Phos village by Mr.Cheam Phen, I would like to ask[Mr. Riththy] to provide a temporary place to stay for these families and construct houses for them on my family's expenses," Mr.Hun Sen wrote in the letter dated Sunday.

The land dispute between the families in Sihanoukville and Mr. Phen is currently pending at the court of Appeal, though Mr. Hun Sen's letter did not address the court case.

Mr. Riththy who was in Keo Phos village yesterday, said that his workers had already started to rebuild the villages' homes and that a road in the area was being repaved.

"We will rebuild the member of houses that they lost," during the eviction, he said.

Villagers yesterday also expressed hope that Mr. Riththy would Help retain their farmland, which has been granted to Mr. Phen be the Council of Ministers.

"Okhna Mong Riththy also said that we will get our farmland back soon," said resident Khuon Sitha. “I am grateful… and I thinkthis will be the end," Ms. Sitha said, adding that the families would now ask the Court of Appeal to dismiss the case.

The order given by Mr. Hun Sen comes just month before the national elections in July.

" Cambodians will thank those who help them, and those who receive help from the prime Minister will vote for him, " said Buon Narith, Provincial coordinator for rights group Licadho.

**អត្រាប្តូរប្រាក់**
*ថ្ងៃច័ន្ទ ទី១៨ ខែមីនា ឆ្នាំ២០១៣*

*ប្រភព៖ អគារប្តូរប្រាក់ លី ហួរ*
*ឌី ញូវយ៉កថែមស៍*

| | | | |
|---|---|---|---|
| ដុល្លារ/រៀល | ៣.៩៨២ | ដុល្លារ/យន់ចិន | ៦,២២០០ |
| ផោនអង់គ្លេស/ដុល្លារ | ១,៥១០០ | ដុល្លារ/ប៉េសូម៉ិកស៊ិក | ១២,៤២០០ |
| អឺរ៉ូ /ដុល្លារ | ១,៣០០០ | ដុល្លារ/ដុល្លារកាណាដា | ១,០២០០ |
| ដុល្លារអូស្ត្រាលី/ដុល្លារ | ១,០៤០០ | ដុល្លារ/ក្រូនដាណឺម៉ាក | ៥,៧៤០០ |
| ដុល្លារ/យេនជប៉ុន | ៩៥,០១០០ | ដុល្លារ/រីងគីតម៉ាឡេស៊ី | ៣,១៣០០ |
| ដុល្លារ/ដុល្លារហុងកុង | ៧,៧៦០០ | ដុល្លារ/ប៉េសូហ្វីលីពីន | ៤០,៦២០០ |
| ដុល្លារ/ដុល្លារសិង្ហបុរី | ១,២៥០០ | ដុល្លារ/ដុល្លារតៃវ៉ាន់ | ២៩,៧៥០០ |
| ដុល្លារ/វុនកូរ៉េខាងត្បូង | ១.១១៤,១៩០០ | ដុល្លារ/រ៉ូពីឥណ្ឌា | ៥៤,១០០០ |
| ដុល្លារ/បាតថៃ | ២៩,៦៣០០ | ដុល្លារ/ដុងវៀតណាម | ២០.៩២០ |

**តម្លៃមាសក្នុងស្រុក**
*ថ្ងៃច័ន្ទ ទី១៨ ខែមីនា ឆ្នាំ២០១៣*

| តម្លៃមាស (ផ្សារអូរឫស្សី) | ទិញចូល | លក់ចេញ | តម្លៃនេះ យកតាម |
|---|---|---|---|
| កាណាឌីយ៉ា (ដុល្លារ/តម្លឹង) | ១.៩២០ | ១.៩៣០ | អគារប្តូរប្រាក់ លី ហួរ |
| គីឡូ (ដុល្លារ/តម្លឹង) | ១.៩២០ | ១.៩៣០ | ២៦.៦៧ តម្លឹង ស្មើនឹង |
| ៩៩% (ដុល្លារ/តម្លឹង) | ១.៩០០ | ១.៩១០ | ១គីឡូក្រាម |
| ៩៧% (ដុល្លារ/តម្លឹង) | ១.៨៦០ | ១.៨៧០ | |

# ឌឹ ឃែមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីភាសាអង់គ្លេស     អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ឃែមបូឌា ដេលី     ច្បាប់ចេញផ្សាយថ្ងៃ អង្គារ៍ ទី០៥ ខែ មិនា ឆ្នាំ២០១៣


តមកទំព័រទី ១១

## ឆាកជីវិត អៀង សារី បងធំទី៣

នៅឆ្នាំ១៩៤៦ ដោយបានដឹកនាំក្រុមនិស្សិតប្រឆាំងនឹងអាណានិគមបារាំង ។ នៅឆ្នាំ១៩៤៧ អៀង សារី បានជួបជាមួយ សាឡុត ស ពេល ដែល សាឡុត ស បានវិលត្រឡប់ពីរៀននៅអនុវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម មករៀននៅសាលាបច្ចេកទេសហៅ"សាលាដែក" ក្នុងខណ្ឌឫស្សីកែវ ។ អៀង សារី និង សាឡុត ស ក៏បានរាប់អានគ្នាជាមិត្តភ័ក្តិយ៉ាងជិតស្និទ្ធ ។

នៅឆ្នាំ១៩៥០ អៀង សារី ទទួលបានអាហារូបករណ៍ទៅរៀននៅទីក្រុងប៉ារីសប្រទេសបារាំង ពោលគឺមួយឆ្នាំក្រោយ សាឡុត ស ។ ក្រោយពីប្រឡងជាប់បាក់ឌុប អៀង សារី បានទៅរៀននៅវិទ្យាស្ថានសិក្សានយោបាយក្រុងប៉ារីស(Institute d´Etudes Politiques de Paris) ។ ក៏ប៉ុន្តែនៅក្នុងបញ្ជីឈ្មោះអតីតនិស្សិតដែលបញ្ចប់ការសិក្សាទទួលបានសញ្ញាបត្រពីវិទ្យាស្ថាននេះ គេមិនឃើញមានឈ្មោះ អៀង សារី នោះទេ ។ នេះមានន័យថា អៀង សារី រៀនមិនបានចប់ទទួលសញ្ញាបត្រផ្នែកវិទ្យាសាស្ត្រនយោបាយពីវិទ្យាស្ថាននេះទេ ។ នៅក្រុងប៉ារីស អៀង សារី និងមិត្តភ័ក្តិម្នាក់ទៀតឈ្មោះ រ័ត្ន សាមឿន ក៏បានផ្តួចផ្តើមគំនិតបង្កើតក្រុមនិស្សិតកុម្មុយនីស្តមួយក្រុមដែលមានឈ្មោះថា"ក្រុមម៉ាក់ស៊ីស" ។ ក្រុមនេះតែងតែជួបប្រជុំគ្នានៅក្នុងផ្ទះរបស់លោក កេង វ៉ាន់សាក់ ។ លោក កេង វ៉ាន់សាក់ ដែលធ្លាប់ស្គាល់ អៀង សារី យ៉ាងច្បាស់តាំងពីកាលនៅភ្នំពេញ បានអះអាងថា អៀង សារី គឺជាមនុស្សមានចរិតកោងកាច និងផ្តាច់ការ ។

អៀង សារី បានរៀបការជាមួយ ខៀវ ធីរិទ្ធ ឬ អៀង ធីរិទ្ធ នៅឆ្នាំ១៩៥១ នៅពេលកំពុងរៀននៅប៉ារីស ។ នៅឆ្នាំ១៩៥២ ក្រោយពីរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមបានកាត់ផ្តាច់អាហារូបករណ៍ អៀង សារី រួមជាមួយមិត្តភ័ក្តិមួយចំនួនទៀតដូចជា ហ៊ូ យន់ និង សុន សេន ជាដើមបានសម្រេចចិត្តបន្តស្នាក់នៅប្រទេសបារាំងតទៅទៀត ។ ចំណែកឯ សាឡុត ស និង រ័ត្ន សាមឿន ដែលជាដៃគូរបស់ អៀង សារី បានវិលត្រឡប់មកប្រទេសកម្ពុជាមុន ។ នៅឆ្នាំ១៩៥៧ ទើប អៀង សារី និង អៀង ធីរិទ្ធ វិលត្រឡប់ពីប្រទេសបារាំងវិញ ហើយបានទៅរស់នៅក្នុងផ្ទះជាមួយ សាឡុត ស និង ខៀវ ប៉ុណ្ណារី ដែលត្រូវជាបងស្រីបង្កើតរបស់ អៀង ធីរិទ្ធ ។ អៀង សារី បានចូលធ្វើការជាគ្រូបង្រៀននៅវិទ្យាល័យឯកជនមួយឈ្មោះ "វិទ្យាល័យកម្ពុជបុត្រ" ។ ក្នុងពេលជាមួយគ្នា អៀង សារី បានលបលួចធ្វើការដោយសម្ងាត់ឱ្យពួកកុម្មុយនីស្តដែលពេលនោះ បានបង្កើតបក្សមួយដាក់ឈ្មោះថា "ប្រជាជន" ដើម្បីចូលរួមក្នុងការបោះឆ្នោតជាតិ ។

នៅខែកញ្ញា ឆ្នាំ១៩៦០ អៀង សារី បានក្លាយជាសមាជិកគណៈអចិន្ត្រៃយ៍បក្សពលករកម្ពុជា អតីតបក្សប្រជាជនបដិវត្តន៍ខ្មែរ ។ នៅពេលនោះ ក្នុងចំណោមសមាជិកគណៈអចិន្ត្រៃយ៍ អៀង សារី គឺជាមនុស្សតែម្នាក់គត់ដែលមិនមែនជាសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិន ។ ការដែល អៀង សារី បានចូលក្នុងស្ថាប័នកំពូលនៃបក្សកុម្មុយនីស្តនៅពេលនោះប្រហែលដោយសារតែ អៀង សារី គឺជាមិត្តភ័ក្តិរបស់ សាឡុត ស ដែលនៅពេលនោះគឺជាមេដឹកនាំលំដាប់ទី៣ក្នុងបក្ស និងជាជំនួយការផ្ទាល់របស់ ទូ សាមុត ដែលជាលេខាបក្ស ។ នៅក្រោយពេលដែល ទូ សាមុត បាត់ខ្លួន ហើយ សាឡុត ស បានក្លាយជាលេខាបក្សនៅខែកុម្ភៈ ឆ្នាំ១៩៦៣ អៀង សារី ក៏បានឡើងជាមេដឹកនាំ



លោក អៀង សារី របបខ្មែរក្រហម

លំដាប់ទី៣ បន្ទាប់ពី នួន ជា ដែលជាអនុលេខាបក្ស ។ នៅឆ្នាំដដែលនោះ អៀង សារី បានរត់ចេញពីភ្នំពេញទៅលាក់ខ្លួនក្នុងព្រៃជាមួយ សាឡុត ស ។ នៅពេលដែល សាឡុត ស ទៅលាក់ខ្លួនក្នុងមន្ទីរ១០០ ក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម អៀង សារី ក៏នៅទីនោះដែរ ។ អៀង សារី បានប្រើឈ្មោះបដិវត្តន៍ថា "មិត្តវ៉ាន់" ។

នៅក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ អៀង សារី ត្រូវបានតែងតាំងឱ្យធ្វើជាប្រេសិតពិសេសទទួលបន្ទុកផ្នែកទំនាក់ទំនងរវាងសមរភូមិមុខនៅកម្ពុជា និងសម្តេចនរោត្តម សីហនុ ប្រមុខរាជរដ្ឋាភិបាលរួបរួមជាតិ ដែលមានស្នាក់ការនៅទីក្រុងប៉េកាំង ។ ក៏ប៉ុន្តែយោងតាមលោកស្រី Elizabeth Becker បានបញ្ជាក់ថា តួនាទីពិតរបស់ អៀង សារី នៅពេលនោះ គឺឃ្លាំមើល សកម្មភាពរបស់សម្តេចនរោត្តម សីហនុ ។

នៅថ្ងៃទី១៧ មេសា ១៩៧៥ អៀង សារី កំពុងស្ថិតនៅទីក្រុងហាណូយប្រទេសវៀតណាម ។ មួយសប្តាហ៍ក្រោយមកទើប អៀង សារី ធ្វើដំណើរពីហាណូយមកដល់ភ្នំពេញ ។ អៀង សារី ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាជំនួស សារិន ឆាក ។ ក្រោយពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៦ អៀង សារី បានក្លាយជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស ។ អៀង សារី គឺជាមនុស្សតែម្នាក់គត់ដែល ប៉ុល ពត មានទំនុកចិត្តឱ្យធ្វើជាតំណាងបដិវត្តន៍នៃកម្ពុជាប្រជាធិបតេយ្យនៅលើឆាកអន្តរជាតិ ។



អៀង សារី ក្នុងឋានៈជារដ្ឋមន្ត្រីការបរទេស គឺជាអ្នកបញ្ចុះបញ្ចូលបញ្ញវន្តខ្មែរដែលកំពុងនៅក្រៅប្រទេស ជាពិសេសនៅប្រទេសបារាំងឱ្យវិលត្រឡប់ចូលមកកម្ពុជាវិញ ដើម្បីជួយកសាងប្រទេស ។ បញ្ញវន្តខ្មែរវិលត្រឡប់មកប្រទេសកម្ពុជាតាមការបញ្ចុះបញ្ចូលនេះភាគច្រើនសុទ្ធតែត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោល ។

តាមការស្រាវជ្រាវបន្ថែមរបស់លោក ឡុង ដានី ពីប្រវត្តិរបស់ អៀង សារី ហើយបានចុះផ្សាយដោយទស្សនាវដ្តីស្វែងរកការពិតលេខ៨១ ខែកញ្ញា ២០០៦ បានឱ្យដឹងថា អៀង សារី មានស្រុកកំណើតនៅភូមិហ័រឡាក់ B ឃុំលឿងហ័រ ស្រុកចូវថាញ់ ខេត្តត្រាវិញ ។ ផ្ទះកំណើតរបស់ អៀង សារី សង់ពីថ្មផ្ទាល់ដី ដំបូលប្រក់ហ្វ៊ីប្រូស៊ីម៉ងត៍ ។ ក្មួយប្រុស របស់ អៀង សារី ឈ្មោះ ថាច់ វុត្ថា និងក្មួយ ប្រសាឈ្មោះ ហ៊ឹម (ថាច់ វុត្ថា ត្រូវជាកូនរបស់បងស្រី អៀង សារី) ។ វុត្ថា បានឱ្យដឹងថា ឪពុករបស់ អៀង សារី ឈ្មោះ គីម រៀម ជាជនជាតិខ្មែរកម្ពុជាក្រោម និងម្តាយ ឈ្មោះ ច្រិន ធិឡឹយ ជាជនជាតិចិន ដែលរត់មកពីស្រុកចិនតាំងពីតូច៧ជាមួយឪពុកម្តាយ ។

អៀង សារី មានបងប្អូន៣នាក់ ។ បងទី១ ឈ្មោះ គីម ចូវ ភេទប្រុស នៅក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ មានឋានៈជាប្រធានផ្សារអូរឫស្សី ។ នៅអំឡុងទសវត្សរ៍ឆ្នាំ៨០ ចូវ និងក្រុមគ្រួសារបានភៀសខ្លួនទៅរស់នៅរដ្ឋផ្លរីដា សហរដ្ឋអាមេរិក ។ បងទី២ឈ្មោះ គីម ធីកូវ ភេទស្រី មានប្តីឈ្មោះ ថាច់ សុង (បច្ចុប្បន្នស្លាប់ទាំងពីរនាក់ប្តីប្រពន្ធ) ។ កូវ មានកូន៧នាក់រស់នៅប្រទេសកម្ពុជា និង៣នាក់ ទៀតរស់នៅភូមិកំណើត ។

អៀង សារី ជាកូនពៅ ដែលមានឈ្មោះកំណើតថា គីម ស្រ៊ី ។ អៀង សារី បានមករស់នៅស្រុកខ្មែរតាំងពីកុមារភាព ។ អៀង សារី ធ្លាប់បានទៅលេងស្រុកកំណើតម្តងមុនពេលទៅសិក្សានៅប្រទេសបារាំង ។ ពេលនោះ ថាច់ សុង បានលក់ស្រូវ២០០ថាំង ដើម្បីយកថវិកាមកជួយឧបត្ថម្ភ និងជូនដំណើរ អៀង សារី ទៅ រៀននៅប្រទេសបារាំង ៕

## Former Mfone Staff Enter Second Day of Protests

About 300 former employees of bankrupt mobile phone operator Mfone continued to protest yesterday outside the company's closed Phnom Penh offices, demanding severance payments totaling $4.4 million for 1.092 workers. At the same time, 10 employee representatives met with official s from the Ministry of Social Affairs in an unsuccessful bid to resolve the pay issue, protesters and officials said.

"We requested the government, through the ministry, to offer a package for compensating all of us. The government is able to take this money [From the company] in line with the court case," said Nim Solyda, a former engineering super visor with Mfone who attended yesterday's meeting. But Vong Savann, deputy secretary -general of the Labor Dissolution Commission at the Ministry of Social Affairs, Said the government is unable to help the protesters because Mfone had appointed an administrator who is responsible for its debt. "The government is not able to interfere," he said adding that the ministry has scheduled another meeting today with the administrator and the protesters. (Aun Pheap)



Red Rose
RESTAURANT
ភោជនីយដ្ឋាន
កូលាបក្រហម
ម្ចាស់ថ្មី _ម្ហូបឈ្ងុយឆ្ងាញ់
Mon-Sun
8am -8pm
អញ្ជើញមកចូលរួមមិនខកចិត្តទេ សូមអរគុណ!
សម្លម្ជូរ គ្រឿង $11.99
*ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
*សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់
(978) 452-5400
Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851




ហាងមាស គីម ង៉ុក
នៅវេសហាតហ្វឺត
មានលក់ដុំ ឬរាយ ឬដូរ ឬធ្វើប័ណ្ណសំរាប់
អំណោយមានធ្វើប្លែនពន្យាពេលបង់ប្រាក់
-ទទួលឥវ៉ាន់បញ្ចាំ មានចុះថ្លៃរហូតដល់ ៦៥%
សម្រាប់ ពេជ្រមកពីហុងកុង មានជាងអលង្កា
នៅក្នុងហាងជួសជុលបានភ្លាមៗ
ពេលវេលាបើក : ថ្ងៃច័ន្ទ ដល់ថ្ងៃអាទិត្យ
ពីម៉ោង ១០ព្រឹកដល់៧ល្ងាច
KIM NGOC
JEWELRY
金舖
Open: Mon-Sun:
10am-7pm
150 Shield Street Plaza. West Hartdord, CT 06110
Tell: (860) 953-5803, Fax:(860)953-5802




LOWELL
ELDER CARE
978-596-1111
មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល
345 Chelmsford St. Lowell, MA 01851/ 978-596-1111 – www.lowelleldercare.com
អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?
គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។
ទីតាំងនៃមណ្ឌល
ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។
មណ្ឌលផ្តល់សេវាដល់មនុស្សចាស់
• មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
• ការពិនិត្យ និងថែទាំសុខភាព
• ការព្យាបាលតាមរយៈការហាត់ប្រាណ
• កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
• ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
• ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
• កម្មវិធីសិល្បៈ និងតន្ត្រី
• ការអប់រំពីសុខភាព
• ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
• សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល
Our Services
• Door-to-Door Transportation
• Medical Care and Support
• Physical Therapy
• Social Worker
• Khmer Meals and Snacks
• Adaptive Physical Exercise
• Music Programs
• Health Educational Seminars
• Discussions on current events, (and times of reminiscing)
• Outdoor Field Trips
សូមហៅទៅលោក ចន្ទ្រ រស 978 996 6127

តមកទំព័រទី ១

# ឆាកជីវិត អៀង សារី បងធំទី៣



យ៉ាងច្បាស់ដោយសារពេលនេះនៅសល់តែជនត្រូវចោទ២នាក់ទៀតប៉ុណ្ណោះដែលកំពុងដំណើរការកាត់ទោសក្នុងសំណុំរឿង០០២ គឺ នួន ជា និង ខៀវ សំផន ដែលមានវ័យកាន់តែចាស់ជរា ហើយក៏ស្ថិតក្នុងការតាមដានសុខភាពដូចគ្នាដែរ ។

ការស្លាប់របស់ជនជាប់ចោទ អៀង សារី ជាការបាត់បង់សាក្សីដ៏សំខាន់ម្នាក់នៃរបបខ្មែរក្រហមដែលខ្លួនគាត់ផ្ទាល់ត្រូវបានចោទប្រកាន់ ថាចូលរួមចំណែកក្នុងឧក្រិដ្ឋកម្ម និងសោកនាដកម្មទាំងឡាយដែលបានកើតឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥-១៩៧៩ ដូចមាននៅក្នុងដីកាចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត ។ ការបាត់បង់នេះមិនគ្រាន់តែប៉ះពាល់ដល់ដំណើរការស្វែងរកយុត្តិធមិបច្ចុប្បន្ន និងកំណត់ត្រាប្រវត្តិសាស្ត្ររបប



លោក អៀង សារី
ពេលចុះចូលក្នុងឆ្នាំ១៩៩៦

ខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដ៏ធ្ងន់ធ្ងរផងដែរ ចំពោះការទន្ទឹងរង់ចាំរបស់ប្រជាពលរដ្ឋខ្មែរជាច្រើនជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនដែលចូលរួមទាមទាររកយុត្តិធមិក្នុងសំណុំរឿង០០២ប្រឆាំងនឹងជនជាប់ចោទរូបនេះ ។

ជនរងគ្រោះមួយរូបក្នុងរបបខ្មែរក្រហម ហើយជាអ្នកធ្លាប់ជាប់ឃុំក្នុងគុកទួលស្លែង គឺលោក ជុំ ម៉ី មានយោបល់ថា ការកាត់ក្ដីរបស់សាលាក្ដីខ្មែរក្រហមនេះយឺតពេកបានជាធ្វើឱ្យជនជាប់ចោទស្លាប់ដោយមិនទាន់មានសាលក្រមផ្ដន្ទាទោស ។

លោក ជុំ ម៉ី និយាយថា "ការស្លាប់របស់ អៀង សារី ដូចជាការបរាជ័យរបស់សាលាក្ដីខ្មែរក្រហមយ៉ាងអ៊ីចឹងដែរ ។ បានជាខ្ញុំថាអ៊ីចឹងមកពីការកាត់ទោសនោះវាយូរពេកហួសការស្មានការសន្និដ្ឋានរបស់ខ្ញុំមិនដឹងថា នីតិវិធីវាអូសបន្លាយពេលច្រើនឆ្នាំអ៊ីចឹងទេ ។ ឯកសារមានគ្រប់គ្រាន់ទាំងអស់ឯកសាររស់មានគ្រប់គ្រាន់ទាំងអស់ហេតុអ្វីមិនកើត? យើងត្រូវរកពីមូលហេតុ តើមូលហេតុខ្វះអី?" ។

លោក អៀង សារី បានដឹកនាំកម្លាំងឧទ្ទាមខ្មែរក្រហមនៅម៉ាឡៃ និងប៉ៃលិន ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងខែសីហាឆ្នាំ១៩៩៦ ។ លោក និងភរិយារបស់លោក គឺលោកស្រី អៀង ធិរិទ្ធ ត្រូវបានទាហានរាជរដ្ឋាភិបាលចាប់ខ្លួន កាលពីថ្ងៃទី១២ វិច្ឆិកា ឆ្នាំ២០០៧ ដោយត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

សពរបស់លោក អៀង សារី ត្រូវបានដឹកយកទៅធ្វើបុណ្យនៅឯគេហដ្ឋានរបស់លោកក្នុង ភូមិកោះ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ ច្រើនឆ្នាំស្ថិតក្នុងការឃុំខ្លួននៅក្នុងសាលាក្ដីខ្មែរក្រហមលោក អៀង សារី ត្រូវបានតុលាការបើកធ្វើសវនាការច្រើនលើកមកហើយ ប៉ុន្តែលោកពុំដែលបានឆ្លើយទទួលស្គាល់ថា លោកក៏មានចំណែកក្នុងការធ្វើឱ្យប្រជាពលរដ្ឋខ្មែរជាង២លាននាក់បានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ! ។

### ✦ ប្រវត្តិ អៀង សារី ហៅសមមិត្ត វ៉ាន់

ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម អៀង សារី គឺជាមនុស្សស្និទ្ធនឹង ប៉ុល ពត ជាង គេ ។ អៀង សារី និង ប៉ុល ពត បានស្គាល់គ្នា និងជាមិត្តភ័ក្តិយ៉ាងជិតស្និទ្ធនឹងគ្នាតាំងពីពេលរៀននៅភ្នំពេញរហូតបានអាហារូបករណ៍ទៅរៀននៅប្រទេសបារាំង ។ ប្រពន្ធរបស់ អៀង សារី និងប្រពន្ធរបស់ ប៉ុល ពត គឺជាបងប្អូនបង្កើតនឹងគ្នា ។ ក្រោយពេលវិលត្រឡប់ពីប្រទេសបារាំង ប្ដី-ប្រពន្ធ អៀង សារី និង ប៉ុល ពត រស់នៅក្នុងផ្ទះជាមួយគ្នានៅក្រុងភ្នំពេញ ។

អៀង សារី មានឈ្មោះកំណើតថា គីម ត្រាង កើតនៅឆ្នាំ១៩២៥ នៅខេត្តត្រាវិញ កម្ពុជាក្រោម ។ គីម ត្រាង ប្ដូរឈ្មោះមកជា អៀង សារី នៅពេលមករៀននៅកម្ពុជាដើម្បីឱ្យមានសូរសៀងជាឈ្មោះខ្មែរ ។ អៀង សារី បានបន្ថយ អាយុ៤ឆ្នាំ ដោយប្ដូរឆ្នាំកំណើតពី១៩២៥មក១៩២៩វិញ ដើម្បីបានចូលរៀននៅសាលាបឋមសិក្សា ។

នៅឆ្នាំ១៩៤៥ អៀង សារី បានចូលរៀននៅវិទ្យាល័យស៊ីសុវត្ថិ ហើយចូលប្រឡូកក្នុងនយោបាយ **តទៅទំព័រទី ០៩**





សេចក្ដីអញ្ជើញ
You're Invited!
CALL
សហគមន៍ខ្មែរ អាមេរិកាំង
ក្រុងឡូវែល
The Cambodian American League of Lowell, Inc.
សួស្តីឆ្នាំថ្មី គ.ស. ២០១៣
ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៥៥៧
Cambodian New Year 2013 - Year of the Snake 2557
BOARD OF DIRECTORS 2013-2014
OFFICERS
Paul Ratha Yem
Executive Director
Vesna Nuon, President
Bopha Malone, Treasurer
Chanvorn Mom, Clerk
MEMBERS
Chetra Keo, Rida Eng, Montha Kim
The New Year planning committee:
Robin Ith Lunn, Navy Nuon, Chetra Keo
Montha Kim, Pong Lakhana Sathuka Pholy
Bopha Malone, Vesna Nuon, Paul Ratha Yem
សួស្តីឆ្នាំថ្មី ឆ្នាំម្សាញ់ បញ្ចស័ក
ព.ស ២៥៥៧
គ.ស ២០១៣
សហគមន៍ខ្មែរ អាមេរិកាំង ក្រុងឡូវែល
យើងខ្ញុំមានកិត្តិយសសូមគោរពអញ្ជើញ
លោក អ្នកស្រី អ្នកនាងកញ្ញាមកចូលរួមនារាត្រីសមោសរ
ពិសាភោជនាហារ និង រាំកំសាន្ត
ក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ២០១៣
ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៥៥៧
ត្រូវនឹងថ្ងៃ សៅរ៍ ទី៦ ខែមេសា ឆ្នាំ ២០១៣
នៅវេលាម៉ោង ៦ យប់ នៅ
ភោជនីយដ្ឋាន ហុងកុង
308 Westford St., Lowell, MA 01851
តម្លៃសំបុត្រម្នាក់ ២៥ ដុល្លារ
ទំនាក់ទំនងបន្ថែម : លោក យ៉ែម ផល រដ្ឋា
617-459-3000
សហគមន៍ខ្មែរ អាមេរិកាំង
ក្រុងឡូវែល
The Cambodian American League of Lowell, Inc.
Happy Cambodian New Year 2013
Year of the Snake 2557
The Cambodian American League of Lowell, Inc.
cordially invites you to
the Cambodian New Year Celebration 2013
Year of the Snake
Saturday, April 6, 2013 at 6 O'Clock in the evening
Hong Kong Restaurant
308 Westford Street, Lowell, MA 01851
Four Courses Dinner, Cash Bar,
and Dancing with Live Band
Ticket: $25 per person
Properly Attire Required.
More Information, please call
Paul Ratha Yem: 617-459-3000
KhmerXpress.com - TouchDiD@msn.com - 978-902-6693




CAMBODIA
PHONE CARD
Veth Rotana
មិនកាត់នាទី និងមិនផុតកំណត់
សម្លេងច្បាស់ល្អទូរស័ព្ទទៅស្រុកខ្មែរ
4.5¢
per min
Bonus (10%) Min
$10.00 $1 224
$20.00 $2 448
$50.00 $5 1,122
$100.00 $10 2,244
Buy here and get 10% more!
Tel: (978) 942 1641/ (978) 656 8141
(267) 253 3947
www.cambodiaphonecard.us




SIM'S Home Improvement
Major Sim Enterprises, Inc.
ជាងសំណង់តាស៊ីម
License#CS 88569 Registration#153685
978-452-7467 / 978-421-3672 / 978-420-8551
FREE ESTIMATES
60 Middlesex St. (Rte.110) Lowell. MA 01852
FULLY INSURED
Repairing •Remodeling •Additions
ជួសជុល កែលំអរ សង់បន្ថែម
• Kitchen ចង្ក្រានបាយ
• Livingroom បន្ទប់ទទួលភ្ញៀវ
• Bathroom បន្ទប់ទឹក
• Bedroom បន្ទប់ដេក
• Roofing ដំបូល
• Siding ជញ្ជាំង
• Window បង្អួច
• Door ទ្វារ
• Basement ជាន់នៅក្រោមដី
• Additions បន្ទប់បន្ថែម
Residential • Commercial • Industrial
ទទួលប្រាក់គ្រប់ប្រភេទ
Bank Loan, Insurance, Compensation, Credit Debit, Check &Cash
More information call: 1.978.452.7467
www.SimsHomeImprovement.com
Boreth@SimsHomeImprovement.com

# បុណ្យរំលឹកគុណដល់វិរបុរសខ្មែរកម្ពុជាក្រោម

**ហ្វីឡាដែលហ្វៀ ដោយ : បញ្ញសីលា**

ថ្ងៃទី១៦ខែមិនាឆ្នាំ២០១៣មានពិធីបុណ្យរំលឹកដល់គុណូបការៈរបស់វិរបុរសខ្មែរក្រោមដែលបានធ្វើពលិកម្មសាច់ស្រស់ឈាមស្រស់នឹងជីវិតរបស់ខ្លួនដើម្បីជាតិ,សាសនា,ទំនៀមទំលាប់,អតសញ្ញាណជាតិរបស់ខ្លួនឱ្យគង់វង់តរៀងទៅ។ នៅថ្ងៃនេះមានពិធីបុណ្យ២កន្លែងនៅក្រុងហ្វីឡាដែលហ្វៀបានប្រព្រឹត្តទៅយ៉ាងអឹកធឹកនឹងមានភាពស្ងឹងស្ងាតពោរពេញដោយភាពគោរពមួយធ្វើនៅវត្តសុរិយារង្សីភាគខាងជើងនឹងមួយទៀតនៅវត្តផ្លូវលេខ៦ភាគខាងត្បូងនៃទីក្រុងហ្វីឡាដោយក្នុងវត្ថុបំណងតែមួយៈ រំលឹកដល់ការតស៊ូយ៉ាងក្លាហាននឹងឧបការគុណដ៏ធំធេងរបស់បុព្វបុរស,ជាវិរបុរសទាំងឡាយរបស់យើងដែលមើលការស្លាប់ស្រាលដូចរោមសត្វហង្ស តែជាតិសាសនាទំនៀមទំលាប់ប្រពៃណីយ៍នៃជាតិសាសន៏ខ្លួនមានទំងន់ធ្ងន់ជាងភ្នំព្រះសុមេរុៈខ្លួនស្លាប់ក៏ស្លាប់ចុះឱ្យតែអតសញ្ញាណជាតិខ្លួនគង់នៅ។



ពិធីបុណ្យរំលឹកគុណនៃវិរបុរសខ្មែរក្រោមនេះតែងតែប្រព្រឹតធ្វើនៅរៀងរាល់ឆ្នាំតែដោយពុំបានរៀបចំត្រឹមត្រូវនឹងពុំមានលក្ខណៈជាឯកភាព។ នៅលើពិភពលោកនេះទីណាមានសហគមន៏ខ្មែរក្រោមរស់នៅតែងតែបបួលគ្នារៀបចំធ្វើដោយស្ងាត់ស្ងៀមតាមតែក្រុមខ្លួនអាចធ្វើទៅកើតមិនមានកំណត់ថ្ងៃខែជាក់ច្បាស់ទេ។ នៅក្រុងហ្វីឡាតែងតែប្រារព្ធធ្វើរៀងរាល់ឆ្នាំនៅគេហដ្ឋានអ្នកស្រីស៊ីនធីនិត មានភ្ញៀវជិតឆ្ងាយឆ្លងកាត់រដ្ឋផ្សេងៗមកចូលរួមនៅហ្វីឡានេះយ៉ាងកុះករ។ ឆ្នាំនេះមានធ្វើនៅគ្រប់ច្រកល្ហកនៃពិភពលោកទាំងមូលៈ នៅកម្ពុជាក្រោម,នៅប្រទេសកម្ពុជាសឹងតែគ្រប់ខេតក្រុង, នៅអឺរ៉ុប,អូស្រ្តាលី,អាមេរិក,កាណាដា, តែមិនទាន់បានរៀបចំនៅថ្ងៃតែមួយនៅឡើយចាប់ពីឆ្នាំម្សាញ់២០១៣ទៅថ្ងៃរំលឹកគុណដល់វិរៈបុរសខ្មែរកម្ពុជាក្រោមនឹងប្រព្រឹត្តទៅនៅថ្ងៃតែមួយ នៅលើពិភពលោកនេះទាំងមូល។ ដើម្បីភ្ជាប់ខ្មែរកម្ពុជាក្រោមទៅនឹងប្រវត្តិសាស្ត្រកម្ពុជា អ្នកនិពន្ធនៃអត្ថបទនេះសុំស្នើដល់អង្គការសហព័ន្ធខ្មែរកម្ពុជាក្រោម មេត្តាបញ្ចូលវត្តមាននៃបុព្វបុរសដែលជាវិរៈបុរសខ្មែរបានសាងមហានគរទុកឱ្យយើងរស់នៅនឹងការពារដល់សព្វថ្ងៃដោយរៀបរាប់ព្រះនាមនៃមហាក្សត្រមួយចំនួន ដូចយសោវរ្ម័នទី២,ព្រះបាទជ័យវរម្ម័នទី៧,ព្រះបាទអង្គឌួង ។ល.។ រួចយើងឱ្យឈ្មោះថាៈ "បុណ្យរំលឹកគុណចំពោះវិរបុរសខ្មែរដែលបានកសាងមហានគរនឹងវិរបុរសខ្មែរកម្ពុជាក្រោមដែលបានបូជាជីវិតដើម្បីអត្តសញ្ញាណខ្មែរកម្ពុជាក្រោមគង់វង្ស" ។ ឬក៏ឱ្យនាមអ្វីមួយដែលយើងឯកភាពជាមួយគ្នានាពេលក្រោយ។ បើបានដូច្នេះយើងឃើញថាយើងបានភ្ជាប់ខ្លួនជាមួយវិរបុរសដែលបានកសាងមហានគរផង មានឈាមជាអ្នកសាងអង្គរដ៏អស្ចារ្យលើពិភពលោកនេះផង។ ម្យ៉ាងទៀតពិធីនេះធ្វើឱ្យបងប្អូនខ្មែរមួយចំនួនដែលមិនសូវយល់ច្បាស់ពីរឿងបងប្អូនខ្មែរកម្ពុជាក្រោម ចេះតែគិតថា ពួកខ្មែរក្រោមចេះតែចង់បែងចែកខ្មែរក្រោមពីខ្មែរដ៏ទៃឯទៀត, ការពិតមិនមែនដូច្នោះទេ ខ្មែរកម្ពុជាក្រោមគ្នាមានបញ្ហាប្រចាំស្រុកទេសគ្នា ដែលត្រូវដោះស្រាយដោយឡែកមិនមែនជាបញ្ហាសម្រាប់ខ្មែរទូទៅហេតុនេះត្រូវប្រើពាក្យខ្មែរក្រោមជាប្រចាំ ពេលនិយាយកិច្ចការអ្វីផ្សេងៗទាក់ទងដល់មាតុភូមិរបស់គ្នា។ ដោយទំព័រមានកំណត់ខ្ញុំសុំទុករឿងមួយយ៉ាងសំខាន់ ដែកលោកក្បៀងម៉ាន់រិនបានបង្ហើបឱ្យដឹងពីកិច្ចការរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ដើរដល់ផ្លូវបទមួយដែលធ្វើឱ្យយួនភ័យស្លន់ស្លោររកអ្នកជួយកាពារខ្លួនកុំឱ្យសហព័ន្ធខ្មែរកម្ពុជាក្រោមចាក់មួយខ្ចាយអាចមានគ្រោះថ្នាក់រហូតដលប្រកាច់ស្លាប់បាន ដោយក្បាច់ប្រដាល់ទំងន់រុយធ្វើឱ្យទំងន់មាន់ប្រកាច់ខ្វាល់! សុំរង់ចាំអានជាបន្តនៅលេខក្រោយ ៕



ទស្សនៈនយោបាយ

# ការបោះឆ្នោតសកលក្នុងកម្ពុជា នាខែកក្កដាឆ្នាំ២០១៣

**ដោយ ម៉ម យឹន**

**លក្ខណៈទូទៅនៃការបោះឆ្នោត**



ដើម្បីឱ្យបណ្តាប្រជាពលរដ្ឋជាម្ចាស់សន្លឹកឆ្នោតជាអ្នកសម្រេចភ័ព្វព្រេងវាសនារបស់ខ្លួន និងប្រទេសជាតិមាតុភូមិរបស់ខ្លួនឱ្យបានជ្រើសរើសមេដឹកនាំប្រទេសជាតិគ្រប់ស្ថាប័ន និងគ្រប់ជាន់ថ្នាក់សម្រាប់ដឹកនាំគ្រប់គ្រងប្រជាពលរដ្ឋ និងប្រទេសជាតិឱ្យបានបុគ្គលប្រកបដោយគតិបណ្ឌិតមានគុណសម្បត្តិសមត្ថភាពពិតប្រាកដល្អមជាទីពេញចិត្តទុកចិត្ត និងស្រលាញ់នៃបណ្តាប្រជាពលរដ្ឋទូទាំងប្រទេស ។

នៅក្នុងគ្រប់អរិយប្រទេសដែលប្រកាន់យកគោលការណ៍លទ្ធិប្រជាធិបតេយ្យការជ្រើសរើសយកបុគ្គលណាមួយក្នុងចំណោមបេក្ខជនឈរឈ្មោះឱ្យបណ្តាប្រជាពលរដ្ឋជាអ្នកមានសិទ្ធិសេរីភាពពេញបរិបូរណ៍ និងមានស្វ័យសម្រេចចិត្តដោយខ្លួនឯង គឺពុំត្រូវឱ្យមានបេក្ខជន ឬបុគ្គល



ដ៏មានអំណាចណាមួយទៅសូកសែនទិញសន្លឹកឆ្នោតនោះសោះឡើយ ។ ការប្រើអំណាចទៅតាមវិធីសូកសំឡុត និងសម្លាប់នេះបានបណ្តាលឱ្យគណបក្សកាន់អំណាចតែងតែមានប្រៀបយ៉ាងខ្លាំង នៅក្នុងការបោះឆ្នោត ពុំមានអត្ថន័យ និងខ្លឹមសារអ្វីសោះឡើយ ប្រៀបបាននឹងការបោកបញ្ឆោតបណ្តាប្រជាពលរដ្ឋ ឬជាការលួចប្លន់សន្លឹកឆ្នោតដូច្នោះដែរ ធ្វើឱ្យតែខ្លួនបានឈ្នះស៊ីដាច់គេ រួចហើយឡើងកាន់អំណាចធ្វើជាអ្នកធំក្តោបក្តាប់អំណាចតែម្នាក់ឯងតែប៉ុណ្ណោះ ។

ដើម្បីជាការងាយយល់ និងងាយស្រួលក្នុងការសម្រេចចិត្តរបស់បណ្តាប្រជាពលរដ្ឋ ក្នុងការជ្រើសរើសមេដឹកនាំដែលត្រូវតែមានសមត្ថភាព និងគុណសម្បត្តិពេញបរិបូរណ៍ សូមលើកយក

**តទៅទំព័រទី ១៦**



ចលនាប្រជាធិបតេយ្យសង្គ្រោះជាតិ
Cambodia Democratic
Movement for National Rescue

**សេចក្តីថ្លែងការណ៍រួម**

**នៃ**

**ចលនាប្រជាធិបតេយ្យសង្គ្រោះជាតិ**

ក្នុងជំនួបរវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃចលនាប្រជាធិបតេយ្យសង្គ្រោះជាតិ ដឹកនាំដោយ លោក សម រង្ស៊ី និង លោក កឹម សុខា នៅទីក្រុងសិង្ហបុរី ប្រទេសសិង្ហបុរី នាព្រឹកថ្ងៃទី០៦ ខែមិនា ឆ្នាំ២០១៣ បានឯកភាពគ្នាសម្រេចជាគោលការណ៍ដូចខាងក្រោម ៖

១. លោក **សម រង្ស៊ី** នឹងដឹកនាំស្ថាប័ននីតិប្រតិបត្តិ **ជានាយករដ្ឋមន្ត្រី** នៅពេលគណបក្សសង្គ្រោះជាតិឈ្នះឆ្នោត ។

២. លោក **កឹម សុខា** នឹងដឹកនាំស្ថាប័ននីតិបញ្ញត្តិ **ជាប្រធានរដ្ឋសភា** នៅពេលគណបក្សសង្គ្រោះជាតិឈ្នះឆ្នោត ។

៣. **បញ្ជីបេក្ខជនតំណាងរាស្ត្រ**របស់គណបក្សសង្គ្រោះជាតិ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ។

៤. **រចនាសម្ព័ន្ធ**ថ្នាក់ដឹកនាំជាន់ខ្ពស់របស់គណបក្សសង្គ្រោះជាតិ ។

៥. ការបង្កើត**ក្រុមការងារ**សង្គ្រោះជាតិ សម្រាប់សិក្សាស្រាវជ្រាវលើវិស័យនានា ។

៦. **គោលនយោបាយជាយុទ្ធសាស្ត្រ**របស់គណបក្សសង្គ្រោះជាតិ ដែលនឹងដាក់ជូនសមាជលើកដំបូងរបស់គណបក្សសង្គ្រោះជាតិ នាថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៣ ។

ធ្វើនៅទីក្រុងសិង្ហបុរី ថ្ងៃទី០៦ ខែមិនា ឆ្នាំ២០១៣

| សម រង្ស៊ី | កឹម សុខា |
|---|---|
| ប្រធានចលនាប្រជាធិបតេយ្យសង្គ្រោះជាតិ | អនុប្រធានចលនាប្រជាធិបតេយ្យសង្គ្រោះជាតិ |






# ម៉ម សុណង់ដូ រួចទោសជាប់ពីពន្ធនាគារ



លោក ម៉ម សុណង់ដូ អាយុ ៧២ឆ្នាំ ជាប្រធានស្ថានីយ៍វិទ្យុសំបុកឃ្មុំ បានត្រូវប៉ូលិសដោះលែងពីគុកព្រៃស កាលពីព្រឹកថ្ងៃទី ១៥ខែមីនានេះ បន្ទាប់ពីជាប់ទោសពីបទដឹកនាំចលនាតំបន់អប្បគមន៍ ប្រឆាំងរដ្ឋាភិបាល ហើយនៅក្នុងគុកអស់ពេល ៨ ខែ និងបន្ទាប់ពីមានសម្ពាធពីអង្គការកាសែតពិភពលោក អង្គការសិទ្ធិមនុស្ស និងរដ្ឋាភិបាលនៃប្រទេសសេរីជាច្រើន ទៅលើរដ្ឋាភិបាលលោក ហ៊ុន សែន មក។





ការចោទប្រកាន់លើរូបលោក ម៉ម សុណង់ដូ គឺនៅពេលដែលប្រធានវិទ្យុសំបុកឃ្មុំ ស្ថិតនៅប្រទេសបារាំង និងស.រ.អា ចំនួនច្រើនខែ ស្វែងរកធនធានសម្រាប់ទ្រទ្រង់ចលនាប្រជាធិបតេយ្យនៅកម្ពុជារបស់លោក ចំណែកឯនៅកម្ពុជាឯណោះ ប្រជាពលរដ្ឋនៅស្រុកឆ្លូង ខេត្តក្រចេះ រួមគ្នាបះបោរ ប្រឆាំងនិងការយកដីរាស្ត្រដោយក្រុមអាជ្ញាធរ ហើយចលនាបះបោរនោះបានប្រែក្លាយជាចលនាប្រឆាំងនឹងរដ្ឋាភិបាល ដោយមានមនុស្សពីរនាក់អះអាងថា ខ្លួននៅក្នុងចលនាដែលលោក ម៉ម សុណង់ដូ បានបង្កើតឡើង។

កាលពី៨ខែមុនតុលាការ សាលាដំបូងបានដាក់ទោសលោក ម៉ម សុណង់ដូ ឱ្យជាប់គុក២០ឆ្នាំ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣ តុលាការសាលាឧទ្ធរណ៍ បានដាក់ទោសតែចំនួន៥ឆ្នាំវិញ ក្នុងនោះឱ្យជាប់គុកតែត្រឹម៨ខែដែលបានធ្វើឱ្យលោក សុណង់ដូ ជាប់គុករហូតមកដល់ថ្ងៃទី១៥ ខែមីនា ប៉ុណ្ណោះ រីឯទណ្ឌកម្មដែលនៅសល់ គឺឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ។ ជនជាប់ចោទ២រូបដែលជាប់ទោស១០ឆ្នាំ កាលពី១០ខែមុន ក៏ត្រូវដោះលែងឱ្យរួចទោស កាលពីថ្ងៃទី១៦ ខែមីនានេះដែរ ។

លោក ម៉ម សុណង់ដូ មាននិន្នាការមិនស្របតាមនយោបាយរដ្ឋាភិបាលខ្មែរទេ វិទ្យុរបស់លោកជាសម្លេងតែមួយ ដែលគណបក្សប្រឆាំងអាចធ្វើការផ្សព្វផ្សាយបំពងសម្លេងបានក្នុងចំណោមវិទ្យុ និងទូរទស្សន៍ រាប់សិបដែលផ្សាយនៅកម្ពុជា តែលោកពុំមែនជាសមាជិកគណបក្សប្រឆាំងណាមួយទេ៕

***ដោយ : ខ្មែរផុស ស.រ.អា***



តមកពីទំព័រទី ១៤

# ការបោះឆ្នោតសកលក្នុងកម្ពុជា...

លក្ខណៈសំខាន់ៗខ្លះសម្រាប់បញ្ជាក់ក្នុងការបោះឆ្នោតនេះ :

**១-បេក្ខជនជាអ្នកឈរឈ្មោះ**

ដោយយោងទៅតាមច្បាប់រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា បេក្ខជនជាអ្នកឈរឈ្មោះជាតំណាងរាស្ត្រក្តី នៅក្នុងគ្រប់មណ្ឌលបោះឆ្នោតទូទាំងប្រទេស និងជាបេក្ខជនមន្ត្រីគ្រប់ស្ថាប័នគ្រប់ជាន់ថ្នាក់ក្តី ត្រូវតែមានសិទ្ធិសេរីភាព ពេញបរិបូរណ៏ក្នុងការចុះឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។

បេក្ខជនទាំងនោះត្រូវតែខិតខំបង្ហាញប្រាប់ពីជីវប្រវត្តិ និងលក្ខណៈសម្បត្តិ គុណសម្បត្តិ សមត្ថភាពរបស់ខ្លួនផ្សព្វផ្សាយជាសាធារណៈ សម្រាប់ឱ្យសាធារណជនទូទាំងប្រទេសបានដឹងជាពិសេសត្រូវបញ្ចេញបង្ហាញអំពីអតីតភាពចាប់តាំងពីនៅក្នុងវ័យជាយុវភាព ប្រកបការសិក្សា ការបញ្ចប់ការសិក្សា និងការបំពេញមុខនាទីជាពលរដ្ឋដែលប្រកបដោយគតិយុត្តិធមិ សុចរិតទៀងត្រង់ មានចរិយាសម្បត្តិ និងឧត្តមគតិ សតិស្មារតី មនសិការ រហូតមកដល់ពេលវេលាដែលត្រូវស្ម័គ្រចិត្តឈរឈ្មោះជាបេក្ខជននេះ ។

បើសិនជាបេក្ខជនឈរឈ្មោះ ពិតជាមានលក្ខណៈសម្បត្តិល្អត្រឹមត្រូវពិតប្រាកដមែននោះ វាត្រូវតែបានជ្រើសរើសយកឱ្យធ្វើជាតំណាងរាស្ត្រឈានទៅដល់ជាប្រធានាធិបតី ឬជានាយករដ្ឋមន្ត្រី ។

**២-អ្នកមានសិទ្ធិបោះឆ្នោត ឬអ្នកម្ចាស់សន្លឹកឆ្នោត**

តាមធម្មតាពលរដ្ឋដែលមានអាយុគ្រប់១៨ឆ្នាំពេញបរិបូរណ៏ត្រូវតែមានសិទ្ធិពេញលេញជាម្ចាស់សន្លឹកឆ្នោតទៅឱ្យឈ្មោះបេក្ខជនជាតំណាងរាស្ត្ររបស់ខ្លួនណាមួយដែលខ្លួនពេញចិត្តទុកចិត្ត និងស្រលាញ់ ហើយជ្រើសរើសជាតំណាងរាស្ត្ររបស់ខ្លួន និងឱ្យជួយការពារ និងដោះស្រាយនូវគ្រប់បញ្ហាដែលខ្លួនជួបប្រទះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួននោះ ។ ជាពិសេសតំណាងរាស្ត្រដែលខ្លួនបានជ្រើសរើសយកនោះ គឺពិតជាមានលក្ខណៈសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់អាចជួយការពារទ្រទ្រង់ប្រទេសជាតិឱ្យបានរីកចំរើនលូតលាស់គ្រប់វិស័យពិតប្រាកដមែន ។

កត្តាសំខាន់ទាំង២ដែលបានលើកឡើងនេះ គឺគ្រាន់តែជាបុព្វបទដែលឆ្លុះបញ្ចាំងឱ្យឃើញពីការបោះឆ្នោតសកល ប៉ុន្តែនៅមានចំណុចសំខាន់ៗជាច្រើនទៀត ដែលសម្រាប់ឱ្យបណ្តាប្រជាពលរដ្ឋខ្មែរត្រូវតែផ្តោតចិត្តផ្តោតអារម្មណ៏ឱ្យបានខ្លាំងក្លាមែនទែន ពីព្រោះការបោះឆ្នោតជ្រើសរើសយកមន្ត្រីគ្រប់ស្ថាប័ន និងគ្រប់លំដាប់ថ្នាក់ គឺពិតជាមានអត្ថន័យខ្លឹមសារ និងអត្ថប្រយោជន៏ខ្លាំងណាស់ សមស្របទៅតាមច្បាប់រដ្ឋធម្មនុញ្ញ និងឆន្ទះចង់បានរបស់បណ្តាប្រជាពលរដ្ឋដែលជាម្ចាស់នៃសន្លឹកឆ្នោត ហើយនិងជាម្ចាស់ប្រទេសជាតិទាំងមូលទាំងអស់គ្នានោះដែរ ។

ដោយយោងទៅតាមស្ថានភាពនយោបាយនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីក្រោយថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១មក ដែលខ្មែរបានទទួលសន្ធិសញ្ញាអន្តរជាតិ ដើម្បីបញ្ចប់សង្គ្រាមប្រយុទ្ធតស៊ូរំដោះសង្គ្រោះប្រទេសជាតិខ្មែរឱ្យបានរួចចេញផុតពីរបបគ្រប់គ្រងកុម្មុយនីស្តយួនយៀកមិញបន្តុប ក្រុមខ្មែរក្រហម យៀក ចាប់តាំងពីថ្ងៃ ទី៧ ខែមករា ឆ្នាំ១៩៧៩ មកនោះ ។

ក្រុមមេដឹកនាំខ្មែរក្រហមយៀកមិញនេះ ដែលមានក្រុម ហេង សំរិន ជាស៊ីម និង ហ៊ុន សែន ជាមេក្លោង ហើយជាអ្នកមានទឹកចិត្តគោរពស្វាមីភក្តិយ៉ាងប្តូរផ្តាច់បំផុត ដល់មេដឹកនាំយួនកុម្មុយនីស្តក្រុងហាណូយតែងតែខិតខំព្យាយាមក្រាញក្តោបក្តាប់ឱ្យអំណាចឱ្យនៅតែក្នុងក្រុមរបស់ខ្លួនជាប់ជានិច្ច ដើម្បីបំពេញគោលបំណងមហិច្ឆតាលោភលន់ចង់ឈរលេបយកទឹកដីខ្មែររបស់មេដឹកនាំយួនយៀកមិញដែលមានខ្មោចហូជីមិញជាប្រធាននោះ ។

ទោះបីជាមានការប្រយុទ្ធតស៊ូទាមទារឱ្យកងទ័ពយួនក្រហមប្រមាណ២០ម៉ឺននាក់ដកថយចេញ និងមានសន្ធិសញ្ញាអន្តរជាតិ ២៣ តុលា ៩១ តាមកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនោះ យ៉ាងណាក៏ដោយ ក៏ក្រុមមេដឹកនាំខ្មែរក្រហមរណបដាច់ថ្លៃយួនទាំង៣នាក់នេះ នៅតែខិតខំព្យាយាមពង្រឹង និងពង្រីកឥទ្ធិពលអំណាចរបស់ខ្លួនយ៉ាងខ្លាំងក្លាបំផុតធ្វើយ៉ាងណាឱ្យតែបានឈ្នះនៅក្នុងការបោះឆ្នោតម្តងៗពី១ អាណត្តិទៅ១អាណត្តិទៀតជារៀងរហូតមក ។

បើតាមការកត់សម្គាល់ និងតាមដានពិនិត្យមើលយ៉ាងដិតដល់នៅក្នុងប្រព័ន្ធនៃការរៀបចំការបោះឆ្នោតដែលរដ្ឋាភិបាល ហ៊ុន សែន បានបង្កើតឡើងនាឆ្នាំ១៩៩៨ បន្ទាប់ពីបេសកកម្មពិសេសនៃអង្គការសហប្រជាជាតិដែលបានបញ្ចប់ទៅនោះ គឺគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតហៅកាត់ថា "គជប" ជាអង្គការមួយតាមការពិតត្រូវតែជាអង្គការឯករាជ្យអព្យាក្រិត្យឥតលំអៀង មានគតិយុត្តិធមិ ល្អត្រឹមត្រូវ មានតម្លាភាព និងផ្តល់សិទ្ធិសេរីភាពពេញបរិបូរសម្រាប់ផ្តល់យុត្តិធមិទៅឱ្យដល់គ្រប់គណបក្សនយោបាយទាំងអស់ ពុំត្រូវឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើតែគណបក្សប្រជាជនកម្ពុជាដែលជាបក្សកាន់អំណាចផ្តាច់ការតែមួយដូច្នេះឡើយ ។ **តទៅទំព័រទី២០**





ការិយាល័យមេធាវី ដឺរេង នឹង បរូស្គី

LAW OFFICE DOERING & BOROWSKY, LLC

ទទួលការពារផលប្រយោជន៍លោកអ្នក ករណីទូទៅតាមផ្លូវច្បាប់ដូចជា :

. ករណីបើកបរពាណិជ្ជកម្ម និងផ្ទេរប្រាក់ក្នុងមុខជំនួញ
. ករណីទិញលក់អចលនវត្ថុ ដូចជាផ្ទះសម្បែង ដីធ្លីជាដើម
. រើសអើងនៅកន្លែងធ្វើការ
. ករណីអន្តោប្រវេសន៍



ធ្លាប់មានបទពិសោធន៍ខ្ពស់ _ផ្តល់សេវាជីនតាមវិជ្ជាជីវៈហើយតម្លៃក៏សមរម្យទៀតផង _យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។

General practice law office handing matters in :
Corporations and business Transations
Real Estate
Work Place discriminations
Immigration
Experienced, professional service and reasonable rate Interpreter available

Office: (215) 667-8118 1650 Market st. Ste 3600 Philadelphia, PA 19103
Cell: (215) 840-1364; Email: dblawyers@gmail.com


# រូបមន្តបង្ហាប់ស្បែកមុខដោយខ្លួនឯង



▸▸ ដើម្បីដោះស្រាយបញ្ហាស្បែកមុខជ្រីវជ្រួញយារធ្លាក់ដែលជាសញ្ញាបង្ហាញឱ្យឃើញវ័យកាន់តែជរានោះ ស្ត្រីគ្រប់រូបគួរស្វែងយល់ពីវិធីថែទាំស្បែកមុខឱ្យហាប់តឹងណែន ព្រោះវាជួយកាត់បន្ថយវ័យរបស់អ្នកឱ្យកាន់តែក្មេងមួយកម្រិតទៀត ។ ខាងក្រោមនេះយើងនឹងណែនាំពីវិធីបង្ហាប់ស្បែកមុខដោយខ្លួនឯងដោយមិនចាំបាច់ចូលហាងកែសម្ផស្សនោះឡើយ ។

**១-ម៉ាស្សាថ្ពាល់ :** ដាក់បាតដៃនៅសងខាងខ្ទង់ច្រមុះ រួចហើយសន្សឹមៗឈ្លីម៉ាស្សាលើស្បែកដោយប្រើបាតដៃទាំង២រុញស្បែកឡើង រហូតដល់សៀតផ្កា ។ បន្ទាប់មកប្រើបាតដៃទាំងពីរសង្កត់នៅលើស្បែកមុខចំនួន៣ដង ។

**២-បង្កើតរំញ័រ :** ក្រោយពេលទម្លាក់ទម្ងន់ទៅលើបាតដៃទាំងពីរដើម្បីសង្កត់ហើយ បន្ទាប់មកដាក់បាតដៃនៅត្រង់ចំណុចដដែល រួចអង្រួនដៃទាំងពីរឱ្យបានញាប់ដើម្បីបង្កើតកម្លាំងរំញ័រដល់សាច់ថ្ពាល់ប្រមាណ១០វិនាទី ។

**៣-លើកទម្រង់ផ្ទៃមុខ :** ប្រើម្រាមចង្អុល និងម្រាមមេដៃត្បៀតចុងចង្កាឈ្លីម៉ាស្សារុញឡើងទៅលើរហូតដល់ទងត្រចៀកនៅលើផ្ទៃមុខចំហៀងខាងស្តាំដោយប្រើដៃខាងស្តាំ ចំណែកខាងឆ្វេងប្រើដៃខាងឆ្វេងម៉ាស្សាចំនួន៣ដង ។

**៤-សង្កត់ជាចំណុចៗ :** ប្រើម្រាមកណ្តាលចុចសង្កត់តាមចំណុចដើម្បីការពារភាពយារធ្លាក់ដោយសន្សឹមៗសង្កត់រួចហើយប្រលែងដៃមេមកវិញ ។ ចំណុចទីតាំងដែលអាចធ្វើបានគឺនៅបរិវេណក្រោមភ្នែកឃ្លាតឆ្ងាយពីឆ្អឹងរង្វង់ភ្នែកផ្នែកខាងក្រោមប្រមាណ១សង់ទីម៉ែត្រ និងចុចនៅត្រង់ជ្រុងបបូរមាត់ទាំងសងខាង ។

គួរអនុវត្តន៍បែបនេះរៀងរាល់ថ្ងៃនោះនឹងធ្វើឱ្យស្បែកមុខហាប់ណែនល្អលែងមានស្នាមជ្រីវជ្រួញមកបង្កបញ្ហាក្នុងចិត្តទៅទៀត ៕


ANGKOR AUTO SERVICE,INC.
ហាងជួសជុលរថយន្ត "អង្គរ"

Free Estimate

Auto Body and Maintenance



BODY WORKS
Auto glass and windshields
Auto Frame Straightening and Painting

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វ៊ិរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425





Agent: Roeut Chak

PK Property, Inc.
ក្រុមហ៊ុនអចលនវត្ថុ លក់ ជួល គ្រប់ប្រភេទ

ភីខេ ប្រភឺធី (215) 635-5100
Roeut Chak - (267)872-3516
409 West Cheltenham Avenue
Melrose Park, PA 19027

**សម្រាប់បើកភោជនីយដ្ឋានខ្មែរ**
- 5706 N. 5th Street, Philadelphia PA 19120

ពីដើមជាភោជនីយដ្ឋាន ឥឡូវបិទ២០០០sqft បន្ទប់ដេកបី ជាន់ទី២ជា Apt គ្រឿងបរិក្ខាទាំងអស់នៅក្នុងផ្ទះឈ្នួល២០០០/ខែ

5734 N.2nd Street, Philadelphia, PA 19120
២៥០០ sqftពីដើមជាភោជនីយដ្ឋាន មានកន្លែងចតឡាន៧៥- ឈ្នួល ២១០០/ខែ

**កន្លែងភ្នាក់បៀរ BEER DELI**
- $16000/wk, Phila, Asking $99,000w/ Real Estate
- $13000wk, Phila., Asking $79,000w/ Real Estate
- $9000/wk, Asking $320.000
- $13,500/wk Asking $42000

**កន្លែងបោកគក់ដាក់កាត Co. Laundry**
- 100 Machines, 4500 sqft Asking $170,000
- $4500/wk Asking $200000
- 500/wk Bucks County; Asking $350,000

**កន្លែងចែកចាយបៀរ Beer Distributor**
- $1.3 Mil/yr, Bucks County, $250000 yearly income, Asking $1,150,000
- $75000/yr Philadelphia Asking $790,000 with RE
- 11,000,000 Philadelphia Asking $430,000

**សាឡុងធ្វើក្រចក Nail Salon**
- $18000/wk, Montgomery County, Asking $380,000
- $15000/wk South Jersey Asking $370,000

**សូមចូលទៅវេបសាយ**
www.pkpropertyinc.com to check more listings and office information.




**តពីលេខមុន**



តើធ្វើម៉េចទៅខ្ញុំអាចទៅរៀបការបានដែលត្រូវចូលរោងនៅព្រឹកនៃថ្ងៃទី២៨មិនានេះនៅក្នុងចំងាយផ្លូវ១២២គមយ៉ាងនេះ។ ទោះបីម្តាយ"ពុកខ្ញុំឬក៏បងប្រុសបងស្រីជាទីស្រឡាញ់បំផុតរបស់ខ្ញុំក៏ដោយក៏មិនហ៊ានជូនខ្ញុំទៅរៀបការដែរ ក្នុងពេលដ៏គ្រោះថ្នាក់នេះ។ គាត់ទាំងអស់គ្នាគ្រាន់តែទូលមានខ្ញុំថា: "បើអ្នកចេះរក្សាជីវិតអ្នកឱ្យរស់នៅបានក្នុងវេលា នេះអ្នកអាចរៀបការនាងនៅពេលក្រោយបានប្រសិនបើអ្នកបាត់ជីវិតនៅពេលនេះនោះអ្នកនឹងគ្មានបានអ្វីទាំងអស់ "។ ពួកគាត់និយាយត្រូវណាស់ទៅហើយតែធ្វើម៉េចឱ្យខ្ញុំអាចស្តាប់គាត់ទៅកើត? បើរូបភាពនៃសង្សា ជាទីស្រឡាញ់ស្មើធ្លើមប្រមាត់របស់ខ្ញុំត្រូវឈរកណ្តោចកណ្តែងរង់ចាំទទួលស្វាគមន៍ភ្ញៀវតែម្នាក់ឯងនោះដោយទឹកភ្នែកនោះក៏អាចគ្រប់គ្រាន់ធ្វើឱ្យខ្ញុំដាច់រហែកបេះដូងខ្ទេចខ្ទីអស់រលីងគ្មានសល់។ ទេ!ត្រូវតែទៅជាដាច់ខាត! ខ្ញុំមិនអាចបណ្តោយឱ្យនាងឈរតេរតែទៅទោះបីជាជីវិតខ្ញុំនេះត្រូវខ្សែបង់ក៏ដោយ បើពុំដូច្នោះទេគេនឹងនិន្ទានាងថា ជាស្រីត្រូវប្រុសបោកប្រាស់,ត្រូវគេលេងសើចអស់ចិត្ត ហើយគេបោះបង់នាងចោលមិនខ្ជីមករៀបការ។

ខ្ញុំបានកាត់ទៅរកមិត្តសំឡាញ់ដ៏ល្អម្នាក់របស់ខ្ញុំដោយក្តីអស់សង្ឃឹមជាទីបំផុត។ គេបានស្រែកសួរមកខ្ញុំ ដោយងឿងឆល់ថា: " អេ!អាសំឡាញ់ក្រែងថ្ងៃណឹងជាថ្ងៃទី២៨មិនាមែនទេ?"អាសំឡាញ់! ម៉េចឯងក្រាញនៅទីនេះនៅឡើយ? "។ ខ្ញុំឆ្លើយតបវាដោយទឹកភ្នែកហៀរតាមរង្វង់ភ្នែក:"ធ្វើម៉េចគ្នាទៅកើត,បើគ្មានមធ្យោបាយធ្វើដំណើរ? ខ្ញុំបានរត់រកគ្រប់ទីកន្លែងដើម្បីសុំជួល"ម៉ូតូ"គេមួយគ្រឿងតែគ្មានអ្នកណាម្នាក់គេហ៊ានប្រថុយឱ្យជួលឡើយ" សំឡាញ់ខ្ញុំគេហាឡើងនិយាយដោយកំប្លែងលេងសប្បាយឬនិយាយពាក្យពិត ឬយ៉ាងណាមានតែព្រះទេ ទើបជ្រាប : **តទៅលេខក្រោយ**

# Amazing Moment

***By Phien Kim***

across the Mekong River from the East to the West side where we just arrived for few minutes.

My friend happily said: “Wow! The ferry boat is working, that means  we can go, no more Martial Laws, I think.” When we reached the East side of the river bank I stopped by the post office to have a phone call to my future father in laws who were working in the office in front of his mansion across a street and where the telephone with old fashion is available. That telephone needs the speaker to spin a handle while talking.

When the telephone rang I asked the lady who answered the phone to meet the Inspector. She said that the Inspector was busy at home with wedding ceremony. I told that I am the groom who needs to tell him that I am on the way to the wedding ceremony.

She joyfully replied: “Oh that is it? I will go to tell him, he and all the family are waiting for you!” I again got on the motorcycle with the light hearted mind. When we arrived at TX Bridge, 30kms from destination, a group of soldiers with machine guns showing on two sides of the bridge signaled us not to approach them.

My friends asked me: “How do you think Phien?” I slowly answered: “If I am alone I will take the risk to meet them, but I could not ask you to play this peril game, we must do the u turn and I will think after that.” When we got the post office in the East ferry bank where I had phone to my future father in laws, I stopped by and phoned him again.

My friend saw the ferry boat was moving towards the West bank, he rushed and said : “When you got talking you follow me, I will be waiting for you at the West bank.” When I told my future father in laws about the event which didn’t allow me to join my wedding, he replied: “My dear son, don’t worry about the ceremony, keep your life safe we will be happy, take care and return home.” The bride who grasped the phone and said: “Oh my love! How I miss you, make you turn again, but wait for the escort who will bring you back.

The wife of the Provincial Chief is my dearest friend, she can ask her husband to help us. Wait for the  escort at that post office. He can get you easily due to his pass word. May be it gets dark when he reaches there but don’t worry, nothing would happen.

After all, I returned back and met the most beautiful bride that I would regret if I couldn’t see her that night. In the morning my father and mother in laws asked us, my wife and me, to have the breakfast together.

They said: “You have saved our family s’ honor, some bad guys tried to dishonor us by saying that the bride is cheated by a boy who quit her after a long enjoyment.” I felt hot on my face, hatred in my heart. How ferocious words! which would be spilled out from the beasts’ mouth, not from the mouth of human beings.

I needed to say something to reduce their painful felling: “Mom and Dad, because of me and of the chaotic events of our country you

*Continue next Issue*




**ហាងខ្មែរជួសជុលរថយន្ត**

**បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

**Rathe´s Auto Service**

State and Emission
Inspaction General
Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកឺរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376



**ក្រុមហ៊ុនទេសចរណ៍**

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុងនិងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើទិដ្ឋាការសំរាប់ទេសចរណ៍
- ផ្ញើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

CENTURY TRAVEL & SERVICE CENTER
**904 South 8th Street.  Philadelphia, PA 19147**
**Tel : 215-625-2889; Cell : 267-934-9888**



**ខ្មែរជួសជុលរថយន្ត**

**KHMER AUTO REPAIR**

**CAR INSPECTION, DIAGNOTIC & REPAIR**

**ត្រួតពិនិត្យរថយន្តបញ្ជរដ្ឋ**
- ឆែករកកន្លែងខូចខាត និងជួសជុល
- យើងធ្វើហ្វ្រាំង ឬប្រេក
- ត្រួតពិនិត្យធ្វើម៉ាស៊ីនឱ្យស្រួលឡើងវិញ
- បញ្ចេះឡានអាល់ទេណាទ័រ
- បូមចរន្តទឹករ៉េឌីណាទ័រ
- សេវាត្រង់បីស្យង
- មើលតម្រងទ្រនាប់ និងពីញូង

Brake Service
Turn up electronic
Starters Alternators
Radiators water pumps
Transmission Service
Struts checked & serviced
CV Joints Rack & Pinion
Shocks checked & Replace

115 West. Tabor Rd, Philadelphia, PA 19120
Tel: (215) 455-1422/Pat: 215-939-5634

# ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ
# រ.ជ.រ.ប.ខ លោកតា សឺន សាន



**ដោយ : ម៉ម យឺន**

មានន័យថា ពុំទាន់មានជំនួយថវិការាប់ពាន់លានដុល្លារពីប្រទេសណាមួយទេ។

លទ្ធផលនៃការបោះឆ្នោតសកលនាឆ្នាំ១៩៩៣នេះអង្គការអ៊ុនតាក់បានប្រកាសឱ្យដឹងជាផ្លូវការថា គណបក្សហ៊្វុនស៊ិនប៉ិចជាអ្នកទទួលជ័យជំនះ គឺបានទទួលអាសនៈចំនួន៥៨នៅក្នុងរដ្ឋសភាជាតិដែលជាចំនួនច្រើនជាងគេ ។ ដូច្នេះប្រធានគណបក្សហ៊្វុនស៊ិនប៉ិចទ្រង់នរោត្តម រណឫទ្ធិ ត្រូវបានតែងតាំងប្រមុខរដ្ឋាភិបាលខ្មែរនៃប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣នោះមក។

សូមជម្រាបបញ្ជាក់ថា ចាប់តាំងពីក្រោយពេលប្រកាស់លទ្ធផលបោះឆ្នោតសកលឆ្នាំ១៩៩៣នោះមានព្រឹត្តិការសំខាន់ៗជាច្រើនបានផ្ទុះឡើងជាបន្តបន្ទាប់រហូតមកដល់សព្វថ្ងៃ ដូចបានជម្រាបជូនជាលំដាប់លំដោយរួចមកហើយ។



ភាគ១៧-ស្ថានភាពនយោបាយខ្មែរក្រោយពេលបោះឆ្នោតសកលឆ្នាំ១៩៩៣ ពេលគណបក្សប្រជាធិបតេយ្យនិយមព្រះពុទ្ធសាសនាលោកតាសឺន សាន ក្តី គណបក្សប្រជាធិបតេយ្យសេរីនិយមលោកឧត្តមសេនីយ៍ សក់ ស៊ុតសាខន ក្តីពិតមែនតែជាគណបក្សមានដើមកំណើតចេញមកពីរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ តែមួយដូចគ្នាមែនហើយជារណសិរ្សជាតិដែលមានគោលការណ៍ និងគោលជំហរដ៏ល្អប្រសើរត្រឹមត្រូវចំពោះប្រទេសជាតិមាតុភូមិដោយទឹកចិត្តប្តូរផ្តាច់យ៉ាងណាក្តីក៏រណសិរ្សជាតិនេះ នៅតែជាគោលដៅធំបំផុតរបស់កងទ័ពយួនក្រហម និងក្រុមមេដឹកនាំខ្មែរមានខ្សែញាក់របស់កងទ័ពយួនយ៉ាងខ្លាំងក្លាបំផុតហើយត្រូវតែកំចាត់កំចាយកំបាក់បំបែកឱ្យខ្ចាត់ខ្ចាយរលាយអស់កុំឱ្យមានសល់ឡើយ។

នៅក្នុងគោលដៅនេះហើយ ទើបមេដឹកនាំខ្មែរក្រោមខ្សែញាក់របស់យួនបានចាប់ផ្តើមរិះរកវិធីរំលាយគណបក្សប្រជាធិបតេយ្យសេរីទាំងពីរឱ្យរលាយបាត់មុនគេ ចាប់តាំងពីមុនឆ្នាំ១៩៩៨នោះមកផងដែរ។

លោកប្រធាន សឺន សាន នៅក្នុងរយៈពេលដឹកនាំរណសិរ្សជាតិរំដោះលោកតែងតែមានសហការីជិតស្និទ្ធ និងទុកចិត្តទុកថ្លើមបំផុតសម្រាប់ជួយធ្វើកិច្ចការធំៗសំខាន់ៗក្នុងចំណោមនោះ មានលោក អៀង មូលី ដែលជាយុវជនវ័យក្មេងម្នាក់មានចំណេះដឹងល្មមសមគួរអាចធ្វើឱ្យលោកប្រធាន សឺន សាន ស្រឡាញ់ និងទុកចិត្តទុកដូចជាកូនបង្កើតរបស់ទៅទៀត រួមជាមួយកូនបង្កើតរបស់គាត់ឈ្មោះ សឺន សូបេរ្ត៍ និងសឺន រម្មនា ដែលរស់នៅប្រទេសបារាំង។

លោកប្រធាន សឺន សាន ស្រឡាញ់លោក អៀង មូលី ជាងកូនបង្កើតលោកទៅទៀត លោកបានទុកចិត្ត និងប្រគល់កិច្ចការធំៗទៅលើរូប អៀង មូលី តាំងពីពេលបង្កបង្កើតរណសិរ្សជាតិរហូតដល់ពេលបង្កើតគណបក្សនយោបាយចូលមករួបរួមក្នុងសង្គមជាតិខ្មែរ តាមកិច្ចព្រមព្រៀងសន្តិសីទក្រុងប៉ារីសថ្ងៃ២៣តុលា១៩៩១។

នៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៣ គណបក្សលោកតា សឺន សាន បានទទួលកៅអីមួយចំនួននៅក្នុងរដ្ឋសភាជាតិ ចំណែកលោកឧត្តមសេនីយ៍ សក់ ស៊ុតសាខន ពុំមានអាសនៈទេ។

នៅក្នុងអាណត្តិទី១ មានរយៈពេល៥ឆ្នាំ មានកើតការទាស់ទែងខ្វែងគំណិតគ្នា នៅក្នុងចំណោមតំណាងរាស្ត្រមួយចំនួនរបស់លោកតា សឺន សាន នោះ ដែលកើតចេញមកលោក អៀង មូលី មានគម្រោងក្បត់លោកតា សឺន សាន ចង់ធ្វើបក្សប្រហារដកលោកប្រធាន សឺន សាន ចេញពីប្រធានគណបក្ស ហើយលើកលោក អៀង មូលី ឱ្យធ្វើជាប្រធានគណបក្សថ្មីជំនួសវិញ ។

ដោយសារតែជម្លោះបែកបាក់គ្នានេះ លោកតំណាងរាស្ត្រគណបក្ស លោកតា សឺន សាន ឈ្មោះលោក មាស ចន្ទលាភ សម្រេចចិត្តបាញ់សម្លាប់ខ្លួនឯង នៅក្នុងបន្ទប់បរិភោគបាយក្នុងរដ្ឋសភាជាតិនាព្រឹកថ្ងៃអាទិត្យមួយស្លាប់បាត់បង់ជីវិត ទៅ ។

មុននឹងបាញ់សម្លាប់ខ្លួន លោកតំណាងរាស្ត្រមាន ចន្ទលាភ បានសរសេរសំបុត្រមួយទុកថារូបខ្ញុំមានការសោកស្តាយ និងឈឺចាប់ខ្លាំងណាស់ពីការឈ្លោះទាស់ទែងគ្នា រហូតដល់មានការក្បត់លោកតាប្រធាន សឺន សាន ដែលជាទីស្រឡាញ់ប្តូរផ្តាច់របស់ខ្ញុំ ដូច្នេះខ្ញុំមិនសមនៅរស់ឃើញអំពើក្បត់របៀបនេះ តទៅទៀតទេ មានតែស្លាប់ទៅជាការល្អប្រសើរជាង។ **តទៅលេខក្រោយ**


ក្រុមហ៊ុនធានារ៉ាប់រងដែលបាន
បំរើសង្គម២២ឆ្នាំហើយ
CONWAY INSURANCE



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត មុខរបរ និងសុខភាព
**យើងនិយាយភាសាខ្មែរ**

CONWAY INSURANCE AGENCY
P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480
www.ConwayInsurance.com

សូមសួររក Philip Muth, Philip@ConwayInsurance.com

East Coast Center
for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com




**ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន អាការៈដូចជាៈ ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។ និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត**

381 West Broadway South Boston, MA 02127
(617) 464 - 0001

តមកពីទំព័រទី ១៦

## ការបោះឆ្នោតសកលក្នុងកម្ពុជា...

ការប្រព្រឹត្តអំពើអយុត្តិធមិរបស់ "គជប" នេះ គឺជាកំហុសមួយធំណាស់ ក្នុងការបោះឆ្នោតម្តងៗ ពីព្រោះវាផ្ទុយគ្នាស្រឡះពីអត្ថន័យខ្លឹមសារ និងអត្ថប្រយោជន៏ដ៏ធំបំផុតរបស់ការបោះឆ្នោត ដែលមានគោលបំណងចង់បានមន្ត្រីជាអ្នកបំរើជាតិដែលមានលក្ខណៈសម្បត្តិគុណសម្បត្តិ សមត្ថភាពគ្រប់គ្រាន់ ដើម្បីជួយទ្រទ្រង់ការពារផលប្រយោជន៏ប្រទេស និងប្រជាជាតិខ្មែរ ជាពិសេស គជប គឺជាអង្គការកំពូល១ សម្រាប់រៀបចំការបោះឆ្នោតឱ្យបានជ្រើសរើសយកមន្ត្រីគ្រប់ស្ថាប័ន និងគ្រប់ជាន់ថ្នាក់ដែលជាអ្នកទទួលខុសត្រូវចំពោះភ័ព្វព្រេងវាសនានៃប្រទេស និងប្រជាជាតិខ្មែរទាំងមូល និងទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រខ្មែរ មិនត្រូវគិតតែជ្រើសរើសយកមន្ត្រី ជាពិសេសនាយករដ្ឋមន្ត្រីដែលជាបុគ្គលគ្មានលក្ខណៈសម្បត្តិ គ្មានគុណសម្បត្តិសមត្ថភាព គ្មានគុណធមិ គ្មានសីលធមិ គ្មានយុត្តិធមិ និងគ្មានឧត្តមគតិ មនសិការ ស្នេហាជាតិ ខ្មែរសោះ ហើយគិតតែខំក្រាញឱបអំណាចប្រមូលផ្តុំអំណាចឱ្យមកនៅក្នុងកណ្តាប់ដៃតែម្នាក់ឯង ។

នៅខែកក្កដា ឆ្នាំ២០១៣នេះបណ្តាប្រជាពលរដ្ឋខ្មែរត្រូវតែតាំងចិត្តសារជាថ្មីបើកភ្នែកទាំង២សំឡឹងមើលឱ្យឃើញច្បាស់ និងបើកត្រចៀកទាំង២ផ្ទៀងស្តាប់ឱ្យឮច្បាស់ពីស្ថានភាពជីវិតរស់នៅរបស់បណ្តាប្រជាពលរដ្ឋលើពិភពលោកដែលមានមេដឹកនាំដ៏ល្អត្រឹមត្រូវមានគតិបណ្ឌិតយុត្តិធមិ មានលក្ខណៈសម្បត្តិ សមត្ថភាព គុណសម្បត្តិគ្រប់គ្រាន់ ដែលត្រូវបានបណ្តាប្រជាពលរដ្ឋគេនាំគ្នាជ្រើសតាំងឡើងឱ្យធ្វើជាប្រធានាធិបតីជានាកយករដ្ឋមន្ត្រីដោយសមស្របទៅតាមច្បាប់រដ្ឋធម្មនុញ្ញនិតិរដ្ឋ មានតម្លាភាព និងមានគតិយុត្តិធមិ ។

នៅក្នុងការបោះឆ្នោតសកលខែកក្កដាឆ្នាំ២០១៣ ខាងមុខនេះ គឺអាណត្តិទី៥ហើយ ដែលបណ្តាប្រជាពលរដ្ឋខ្មែរ ពុំត្រូវបោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយកុម្មុយនីស្តប្រជាជនកម្ពុជាដែលគេបានស្គាល់ច្បាស់គ្រប់គ្នាថា ជាគណបក្សបង្កើតឡើងដោយប្រធានគណបក្សកុម្មុយនីស្តទាំង៣ប្រទេស គឺខ្មែរ យួន និងលាវ ។

អំពើប្រព្រឹត្តទាំងប៉ុន្មាន នៅក្នុងសកម្មភាពនយោបាយរបស់គណបក្សកុម្មុយនីស្តប្រជាជនកម្ពុជាអស់រយៈពេលជាង៣០ឆ្នាំកន្លងមក ហើយនេះ បានបញ្ជាក់បង្ហាញឱ្យឃើញថា នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាអនុប្រធានបក្សកុម្មុយនីស្តប្រជាជនកម្ពុជាបានត្រូវបណ្តាសមាជិកបក្សនេះប្រគល់អំណាចផ្តាច់ការឱ្យបានធ្វើជានាយករដ្ឋមន្ត្រីរាល់ៗអាណត្តិរហូតអស់មួយជីវិតនៅក្នុងការបោះឆ្នោតពី១ អាណត្តិទៅ១អាណត្តិទៀត ទោះបីការបោះឆ្នោតនោះត្រូវបានគណបក្សប្រឆាំងដ៏ធំប៉ុណ្ណាមកចង់ដណ្តើមជ័យជំនះដោយប្រើវិធីសាស្ត្រខ្លាំងក្លាប៉ុណ្ណាមានប្រជាប្រិយ និងគុណសម្បត្តិ សមត្ថភាពគ្រប់គ្រាន់ប៉ុណ្ណា យ៉ាងណាក៏ដោយក៏បក្សកាន់អំណាចនេះ ត្រូវតែប្រើប្រាស់យុទ្ធសាស្ត្រគ្រប់ឧបាយកលល្បិច គ្រប់អំណាចផ្តាច់ការធ្វើយ៉ាងណាឱ្យទាល់តែទទួលបានជោគជ័យលើគណបក្សប្រឆាំងជាដាច់ខាតតែប៉ុណ្ណោះ ។

ការបោះឆ្នោតដែលប្រកបដោយរបៀបរបបទខាងលើនេះមានន័យថា គណបក្សកាន់អំណាចមានគោលបំណង និងគោលដៅបានរៀបចំទុកមកជាស្រេចរួចអស់ទៅហើយ ដើម្បីធ្វើយ៉ាងណាថា ការបោះឆ្នោតនេះគ្រាន់តែជាឡប់ឡែមួយបញ្ជាក់បង្ហាញដល់មតិជាតិខ្មែរ និងមតិអន្តរជាតិថា ប្រទេសខ្មែរមានមេដឹកនាំជានាយករដ្ឋមន្ត្រី

តទៅទំព័រទី២២

**លក់ឡាជំរែង លក់ម្ហូប**

**Philadelphia:** លក់ឡាន លក់ម្ហូបអាហារ ជ្រុងផ្លូវ 32 និង Market Street Philadelphia នៅសាលា Drexal មានមនុស្សចេញចូលច្រើន - ប្រាក់ចំណូល $7,000 ក្នុងមួយអាទិត្យ -ទុកគ្រឿងប្រដាប់ប្រដាធ្វើការឱ្យទាំងអស់ ម្ចាស់ឡានប្រញាប់លក់ដោយមានធុរៈ

សូមទូរស័ព្ទ : **(267) 455 7333**

**ហ្វ្រេីជិនខ្មែររីដេអ្ញូ**

មានជួលនិងលក់កុនចិន-ថៃ-ខ្មែរ-ឥណ្ឌាគ្រប់ប្រភេទមានចម្រៀងសម័យរីដេអ្ញូ ខារ៉ាអូរខេថ្មីៗ

742 Pottess Avenue

Providence, RI 02907 ទូរស័ព្ទ : **(401) 787 6663**

## ជោគជតារាសីទាំង 12 ប្រចាំឆ្នាំហោង

ជោគជតាប្រចាំសប្តាហ៍

**ឆ្នាំជូត**

រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នាជាយូរមកហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណងហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងយាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហា គូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលរមាស់អ្វីឡើយ ៕

**ឆ្នាំថោះ**

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលរមាស់អ្វីនោះឡើយ ៕

**ឆ្នាំមមី**

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះ ប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបានដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

**ឆ្នាំរកា**

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះៗនាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើអាចរកផលកម្រៃត្រឡប់មកផ្ទះវិញយ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀបដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

**ឆ្នាំឆ្លូវ**

អាចពោលបានថា លោកអ្នកមានសេចក្តីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរនៅទីណាក្តីគួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

**ឆ្នាំរោង**

នៅក្នុងរយៈពេលនេះ លោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៏ដល់ជាតិនិងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើ តែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

**ឆ្នាំមមែ**

ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះឯង ៕

**ឆ្នាំច**

រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មីទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

**ឆ្នាំខាល**

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិតៗ ទើបសមប្រកប ។រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

**ឆ្នាំម្សាញ់**

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះសូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

**ឆ្នាំវក**

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្មុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

**ឆ្នាំកុរ**

រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈពេលនេះ សុទ្ធតែផ្តល់នូវអត្ថប្រយោជន៏គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវកររកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នាបើនៅឆ្ងាយ ៕



មានមធ្យោបាយប្រសើរមួយ ។
អ្នកមិនគួរចាំបាច់ប្រឹងហួសហេតុពេកដើម្បីមានសុខភាពល្អទេ ។
នោះគឺជាមូលហេតុដែលផែនការ CHIP និង Medicaid របស់យើងផ្តល់ជូន:
• សមាជិកភាព Y និង Fitness Center
• Weight Watchers®
តម្លៃរហូតដល់ត្រឹមតែ $1,100 ក្នុងមួយឆ្នាំ!
HEALTH PARTNERS
1-800-553-0784
www.healthpart.com
chip
Pennsylvania's Children's Health Insurance Program
www.chipcoverspakids.com
KidzPARTNERS
1-888-888-1211
www.kidzpartners.com




ផ្សារអាតាឡង់ទីក
Atlantic Market
135 main St, Danbury, CT 06810
203-830-3068
ផ្សារនេះមានម្ចាស់ឈ្មោះ ដាន់ ស៊ីង បើកលក់ដូរតាំងពី១០ឆ្នាំមកហើយ ជាពិសេសយើងជាអ្នកលក់ត្រីស្រស់ៗនៅក្នុងក្រុង ។ បន្ថែមពីលើលក់ត្រីស្រស់ យើងមានលក់បន្លែសម្រាប់ម្ហូបអាស៊ី ។
យើងទទួលយក : American Express -លុយសុទ្ធ -Debit card -Master Card -Visa
បើកទ្វារ : ថ្ងៃច័ន្ទ ម៉ោង ៩:៣០ព្រឹក ដល់៧ល្ងាច/ ថ្ងៃអង្គារ៍ ដល់ថ្ងៃសៅរ៍ ៩:៣០ដល់៨ល្ងាច/ ថ្ងៃអាទិត្យ ៩:៣០-៧:០០
ទីធ្លាចតរថយន្តឥតគិតថ្លៃ

តមកពីទំព័រទី ២០

## ការបោះឆ្នោតសកលក្នុងកម្ពុជា...

កើតចេញមកពីបោះឆ្នោតសកលតាមបែបបទគោលការណ៍លទ្ធិប្រជាធិបតេយ្យរបស់សន្ធិសញ្ញាអន្តរជាតិ ២៣តុលា១៩៩១ ក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដែលបានតម្រូវប្រទេសកម្ពុជា ជាប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនោះតែប៉ុណ្ណោះ ។

ក្នុងនាមរូបខ្ញុំ ម៉ម យីន រស់នៅ ស.រ.អា នៅក្នុងទស្សនៈមតិខ្ញុំថ្ងៃនេះ ខ្ញុំសូមផ្ញើសារអំពាវនាវម្តងទៀតថា: សូមបណ្តាប្រជាពលរដ្ឋរួមជាតិខ្មែរដែលជាម្ចាស់សន្លឹកឆ្នោតដ៏សែនមានតម្លៃសម្រាប់ការបោះឆ្នោតជ្រើសរើសយកមន្ត្រីឱ្យបានធ្វើជាតំណាងខ្លួនឱ្យក្លាយទៅជាតំណាងរាស្ត្រចូលកាន់មុខតំណែងនៅក្នុងមន្ទីររដ្ឋសភាជាតិដូចបណ្តាមហាជនរួមជាតិខ្មែរបានយល់ដឹង និងឃើញយ៉ាងសព្វគ្រប់មកហើយថា ចំនួន៤អាណត្តិឃើញមានតែមន្ត្រីនៅក្នុងរដ្ឋសភា ក៏ដូចគ្នានៅក្នុងរដ្ឋាភិបាល និងតុលាការដែលសុទ្ធតែចេញមកពីគណបក្សកុម្មុយនីស្តប្រជាជនកម្ពុជាតែ១គត់បានកាន់អំណាចដោយប្រកាន់យកគោលការណ៍បក្សជាធំមិនមែនជាតិជាធំនោះឡើយ ។ ម្ល៉ោះហើយប្រព័ន្ធនយោបាយរបស់បក្សនេះ គេសង្កត់យ៉ាងធ្ងន់ទៅលើតែផលប្រយោជន៍របស់បក្សពុំដែលគិតគូរខ្វល់ខ្វាយអ្វីទាល់តែសោះ ។ ជាពិសេសនៅមុនពេលបោះឆ្នោតម្តង១មន្ត្រីនៃបក្សចាប់តាំងពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រធានរដ្ឋសភាទាំង២ សមាជិកសមាជិកាតំណាងរាស្ត្រ និងបេក្ខជនទាំងអស់ត្រូវតែប្រើប្រាស់គ្រប់យុទ្ធសាស្ត្រ គ្រប់ឧបាយកលល្បិច និងគ្រប់អំណាច និងបុណ្យសក្តិលុយកាក់ដែលពួកនេះមានយ៉ាងមហាសាលយកទៅដើរទិញសន្លឹកឆ្នោត ឬដើរប្លន់សន្លឹកឆ្នោតពីបណ្តាប្រជាពលរដ្ឋខ្មែរដែលកំពុងតែរស់នៅក្នុងភាពល្ងង់ខ្លៅភ័យខ្លាច និងអត់ឃ្លានយ៉ាងគួរឱ្យអាណោចអាធមយ៉ាងក្រៃលែងនោះ ។

ចំនួន៤អាណត្តិកន្លងទៅហើយ ដែលបណ្តាមហាជនរួមជាតិខ្មែរបានបោះឆ្នោតប្រគល់ភ័ព្វព្រេងវាសនារបស់ខ្លួន និងជាតិមាតុភូមិខ្លួនឱ្យបានថ្កើងថ្កានថ្លៃថ្នូរបានគង់វង្សទឹកដី និងអត្តសញ្ញាណជាតិខ្មែរ ប៉ុន្តែផ្ទុយទៅវិញ ពី១អាណត្តិទៅ១អាណត្តិអ្វី១ដែលជាលក្ខណៈសម្បត្តិជាជាតិខ្មែរជារបស់ជាតិខ្មែរជាកម្មសិទ្ធិ និងជាសិទ្ធិសេរីភាពរបស់ជាតិខ្មែរត្រូវបានបាត់បង់ទៅបន្តិចម្តង១ជាប់ជានិច្ច ។

នៅក្នុងអាណត្តិទី៥នេះ គឺជាពេលវេលាចុងក្រោយហើយ **តទៅលេខក្រោយ**






"នាងប្រាប់ខ្ញុំគ្រប់យ៉ាង
ខ្ញុំសប្បាយចិត្តខ្លាំងណាស់។
នាងពេញចិត្តនៅផ្ទះជាមួយយើង។"



CAREGIVER™ HOMES

Caregiver Homes™ ជួយចាស់ជរា និងជនពិការឱ្យរីករាយជាមួយ នឹងគុណភាពខ្ពស់នៃជីវិតនៅផ្ទះ

- បង់ប្រាក់ & បង្រៀបណ្ដុះបណ្ដាល អ្នកថែទាំពេញពេលដែលរស់នៅជាមួយ
- ផ្ដល់ជំនួយ ប្រកបដោយវិជ្ជាជីវៈ ពីគិលានុបដ្ឋាយិកា និង អ្នកថែទាំ ដែលចេះយកចិត្តទុកដាក់
- ជួយអ្នកស្វែងរក & ទទួលបានគ្រប់សេវាដែលចាំបាច់

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង **866.797.2333** ឬចូលមកគេហ៍ទំព័ររបស់យើង។
WWW.CAREGIVERHOMES.COM

# មជ្ឈមណ្ឌលសុខភាពពេលថ្ងៃសម្រាប់ជនពេញវ័យ
# HOME AWAY FROM HOME ADULT DAY HEALTH CENTER

នៅពេលលោកអ្នក ឬមនុស្សសំណព្វចិត្តរបស់លោកអ្នកត្រូវការគេជួយនៅពេលថ្ងៃ មជ្ឈមណ្ឌលយើងមានសេវាកម្មអ្នកថែទាំមានវិជ្ជាជីវៈ អាចនិយាយភាសាអង់គ្លេស ខ្មែរ ចិន និងស្ប៉ានីសបាន ។



**យើងអាចផ្ដល់ជូនសេវា ដូចតទៅ :**
- ថែទាំ សំអាត ធ្វើការសង្គមកិច្ចជូន និងព្យាបាលរាងកាយ
- ដឹកជញ្ជូនទៅមកពីផ្ទះទៅមជ្ឈមណ្ឌល និងទៅជួបពេទ្យ
- នាំចេញទៅភោជនីយដ្ឋានខ្មែរ –ទៅទិញឥវ៉ាន់ផ្សេងៗ ឬទៅមើលកន្លែងវប្បធម៌នានា
- មានការស្ដាប់ និងលេងភ្លេង មើលកុន កំសាន្តល្បែង ថ្នាក់សិក្សា និងការហាត់ប្រាណរាល់ថ្ងៃ
- បើកទ្វារពីថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍ ពីម៉ោង៧ព្រឹកដល់៤ល្ងាច ឬក៏ប្ដូរម៉ោងក៏បានតាមតម្រូវការ



**យើងទទួល អ៊ិនសួរិន ស្ទើរគ្រប់មុខ**
- Mass Health • Evercare • Navicare • Senior Whole Health • Elder Services of the Merrimack Valley

## Our Services and Programs
- Nursing, social work and physical therapy
- Transportations
- Breakfast, lunch and snacks
- Outings to Cambodian restaurants, shopping, and cultural events
- Entertainments, spiritual classes and exercise daily

សូមទាក់ទងទៅ ខារិន បន គ្ការីហ្គាន់ (Karen Bond Garrigan) 978-453 Home (978-453-4663) ដើម្បីនាំទៅមើលមជ្ឈមណ្ឌល
Conveniently located at 150 Industrial Avenue East in Lowell, right off the Lowell Connector
Open Monday-Friday 7-4 and Saturday 7:30-2:00 PM
www.homeawayfromhomeADHC.com




| ថ្ងៃសៅរ៍ ទី១៣ ខែមេសា<br>SATURDAY APRIL 13, 2013 | | | |
|---|---|---|---|
| ៩:០០ | ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ<br>នមស្សការព្រះរតនត្រ័យ<br>សមាទានសីល | 9:00 am | Gathering of guests<br>Paying Homage to the Triple Gems<br>Buddhist Monks Chanting |
| ១០:០០ | រាប់បាត្រ ឧទ្ទិសកុសល<br>ស្តាប់ព្រះសង្ឃសូត្រធម៌ | 10:00 am | Alms Offering & Praying |
| ១១:០០ | វេរចង្ហាន់ប្រគេនព្រះសង្ឃ<br>សូត្រជារបង្សុកូល, ឆាន់ត្រង់<br>និងសំដែងធម៌ទេសនា | 11:00 am | Food Offering to Buddhist monks,<br>Bangskol, Lunch for Mounks<br>Dharma Talk |
| ១២:០០ | អាហារថ្ងៃត្រង់ | 12 noon | Lunch for all guests |
| ១២:៣០ | កម្មវិធីសំដែងសិល្បៈ ក្រុម **របាំអង្គរ**<br>ល្បែងប្រជាប្រិយ៍ខ្មែរ, ពូនភ្នំខ្សាច់ | 12:30 pm | Traditional Dance - **Angkor Dance Troupe**; Khmer Traditional Games<br>Sand Mountain |
| ២:១២ | ពិធីទទួលទេវតាឆ្នាំថ្មី (ព្រះនាមទុង្សទេវី) | 2:12 pm | Welcoming New Year Devata |
| ៣:០០ | រាំលេងកំសាន្តឆ្នាំថ្មី **DJ Chandara Keo** | 3:00 pm | New Year Social Dances with Lowell's most popular **DJ Chandara Keo** |
| ៥:០០ | បញ្ចប់កម្មវិធីបុណ្យចូលឆ្នាំថ្ងៃទី១ | 5:00 pm | Adjourn - Day One |






| ថ្ងៃអាទិត្យ ទី១៤ ខែមេសា ឆ្នាំម្សាញ់ បញ្ចស័ក<br>SUNDAY APRIL 14, 2013 | | | |
|---|---|---|---|
| ៩:០០ | ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ<br>នមស្សការព្រះរតនត្រ័យ<br>សមាទានសីល | 9:00 am | Gathering of guests/Pin Peat Music<br>Paying Homage to the Triple Gems<br>Buddhist Monks Chanting |
| ១០:០០ | រាប់បាត្រ ឧទ្ទិសកុសល<br>ស្តាប់ព្រះសង្ឃសូត្រធម៌ | 10:00 am | Alms Offering & Praying |
| ១១:០០ | វេរចង្ហាន់ប្រគេនព្រះសង្ឃ<br>សូត្រជារបង្សុកូល ឆាន់ត្រង់ និង<br>សំដែងធម៌ទេសនា | 11:00 am | Food Offering to Buddhist<br>monks, Bangskol, Luch for Monks<br>Dharma Talk |
| ១២:០០ | អាហារថ្ងៃត្រង់ | 12 noon | Lunch for all guests |
| ១២:៣០ | រាំលេងកំសាន្តឆ្នាំថ្មី ជាមួយក្រុមតន្ត្រី<br>**FANTA-Z** & ល្បែងប្រជាប្រិយ៍ខ្មែរ | 12:30 pm | Live Music: **FANTA-Z** Band<br>Khmer Traditional Games |
| ៣:០០ | ពិធីស្រង់ព្រះ | 3:00 pm | Buddha Statues Cleansing &<br>Blessing Ceremony |
| ៤:០០ | ពិធីឆ្លងភ្នំខ្សាច់ | 4 pm | Sand Mountain Blessing<br>Ceremony |
| ៥:០០ | បញ្ចប់កម្មវិធីបុណ្យចូលឆ្នាំថ្មី | 5 pm | End of Khmer New Year Program |